# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ ក្រុងកំពង់ចាម ឆ្នាំ២០១៨ ដល់២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឡឹក វិច្ឆិកា**

**ក. សុន ឆារី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ឆ្នាំ២០១៩ ដល់២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឡឹក ទិច្ឆិកា**

**ក. សុន ធារី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលរៀន ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាព **ឡឹក ទិច្ឆិកា** និងនាងខ្ញុំ **សុន ធារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២២-២០២៣។

ជាបឋមអាត្មាភាព និងនាងខ្ញុំ សូមសេចក្ដីអនុញ្ញាត ដើម្បីសម្ដែងនូវការគោរពប្រតិបត្តិ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះលោកអ្នកមានគុណទាំងពីរ **លោកឪពុក និងអ្នកម្តាយ** ដែលបានចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ និងបានផ្ដល់ដំបូន្មាន ផ្ដល់ភាពកក់ក្ដៅ សេចក្ដីស្រឡាញ់ ការអនុគ្រោះ អប់រំកូនឱ្យដើរតាមគន្លងធម៌ ដើម្បីក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គម ព្រមទាំងលះបង់នូវកម្លាំងកាយចិត្ត លះបង់ធនធានទំនុកបម្រុងសព្វបែបយ៉ាង និងជំរុញកូនឱ្យបានសិក្សាចាប់ពីថ្នាក់បឋម រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។

សូមគោរពថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យទាំងអស់** ដែលបានខិតខំប្រឹងប្រែងក្នុងការបណ្ដុះបណ្ដាលអភិវឌ្ឍន៍ផ្នែកធនធានមនុស្ស និងបានរៀបចំកម្មវិធីសិក្សាសម្រាប់និស្សិតគ្រប់ជាន់ថ្នាក់ប្រកបដោយភាពរលូន និងភាពជឿទុកចិត្ត។ ជាពិសេស និស្សិតទទួលបាននូវចំណេះដឹង បទពិសោធន៍ សមត្ថភាព ជាច្រើនតាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងជាផ្លូវមួយសម្រាប់ការអភិវឌ្ឍប្រទេសជាតិនៅពេលអនាគតផងដែរ។

សូមគោរពអរគុណដល់ **សាស្ត្រាចារ្យជំនួយ បណ្ឌិត អ៊ុន សកក្កដា** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ជាទីបំផុតក្នុងការកែលម្អ ចង្អុលបង្ហាញ និងផ្ដល់វិធីសាស្ត្រល្អៗ យោបល់ល្អៗទាក់ទងនឹងប្រធានបទសារណា និងបានចំណាយពេលវេលាដ៏មានតម្លៃតាំងពីចាប់ផ្ដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវបានប្រកបដោយភាពជោគជ័យ។

ជាទីបញ្ចប់សូមគោរពជូនពរ លោកអ្នកមានគុណទាំងអស់ សូមទទួលបាននូវសំណាងល្អ សុខភាពល្អ និងទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច ព្រមទាំងសមប្រកបជួបពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយបានឆ្លងកាត់ការសិក្សារយៈពេលបីឆ្នាំកន្លះមកនេះ អាត្មាភាព និងនាងខ្ញុំបានធ្វើការសិក្សាទៅលើកិច្ចការស្រាវជ្រាវជាច្រើនដោយទទួលបានចំណេះដឹងដែលមានការណែនាំ និងការកែសម្រួល ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យជាច្រើន ហើយធ្វើឱ្យចំណេះដឹងមានការរីកចម្រើនជានិច្ចទោះបីជាមិនល្អឥតខ្ចោះក៏ដោយ។ អាត្មាភាព និងនាងខ្ញុំក្នុងនាមជានិស្សិតបានសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំទី៤ ផ្នែកនីតិសាស្ត្រ ពិតជាមានសេចក្តីសប្បាយរីករាយណាស់ ដែលទទួលបានឱកាស និងមានលទ្ធភាពក្នុងការសរសេរសារណាបញ្ចប់ការសិក្សាសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ ហើយការស្រាវជ្រាវមួយនេះអាចស្វង់អំពីចំណេះដឹងតាមរយៈការសិក្សាកន្លងមក និងធ្វើការស្រាវជ្រាវបន្ថែមទៀត។ ដោយទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាបានជំរុញឱ្យអាត្មាភាព និងនាងខ្ញុំបានពិភាក្សាជ្រើសរើសប្រធានបទទាក់ទងនឹងនីតិនគរូបនីយកម្ម និងសំណង់ ស្តីពី "**ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ឆ្នាំ២០១៨ ដល់២០២៣**" មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

អាត្មាភាព និងនាងខ្ញុំសង្ឃឹមថាសារណានេះ អាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយ សាធារណជនដែលចង់ស្វែងយល់អំពីការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម។ បើទោះបីជាប្រធានបទនេះធ្វើការបកស្រាយមិនទាន់បានគ្រប់ជ្រុងជ្រោយ ឬមានការខ្វះចន្លោះយ៉ាងណាក្តី។

មុននឹងបញ្ចប់អាត្មាភាព និងនាងខ្ញុំ សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចខ្វះខាត កំហុសឆ្គង ដែលកើតឡើងដោយអចេតនាលើប្រការណាមួយរួមមាន ការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឬអត្ថន័យខ្លឹមសារនៅក្នុងប្រធានបទនេះ និងសូមស្វាគមន៍ទទួលយកនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាកែលម្អ ដើម្បីឱ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

ជាទីបញ្ចប់ សូមគោរពជូនពរមិត្តអ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ សូមឱ្យទទួលបាននូវសំណាងល្អគ្រប់ពេលវេលា ជោគជ័យគ្រប់ភារកិច្ច ជោគជ័យលើការសិក្សា និងសមប្រកបជួបពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការរៀបចំក្រុងកំពង់ចាម

**១.១. ទិដ្ឋភាពទូទៅ** ........ ៤

១.១.១. ទីតាំងភូមិសាស្រ្ត ........ ៤

១.១.២. ស្ថានភាពប្រជាសាស្រ្ត ........ ៥

**១.២. សមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុង** ........ ៦

១.២.១. សមាសភាព ........ ៦

១.២.១.១. ក្រុមប្រឹក្សាក្រុង ........ ៧

១.២.១.២. គណៈអភិបាលក្រុង ........ ៩

១.២.២. តួនាទី និងភារកិច្ច ........ ៩

១.២.២.១. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ........ ១០

១.២.២.២. តួនាទី និងភារកិច្ចរបស់គណៈអភិបាលក្រុង ........ ១៦

**១.៣. កត្តាជំរុញឱ្យមានការរៀបចំក្រុង** ........ ២២

១.៣.១. កំណើនប្រជាជន ........ ២៣

១.៣.២. ភាពក្រីក្រ ........ ២៤

១.៣.៣. កម្រិតជីវភាពនៃការរស់នៅ ........ ២៥

១.៣.៤. ការដាក់សម្ពាធបរិស្ថាន ........ ២៥

១.៣.៥. គមនាគមន៍ ........ ២៦

## ជំពូកទី២

## ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម

**២.១. បច្ចុប្បន្នភាពការរៀបចំក្រុងកំពង់ចាម** ........ ២៧

២.១.១. ការរៀបចំសោភ័ណភាពក្រុងកំពង់ចាម ........ ២៨

២.១.១.១. សោភ័ណភាពពេលថ្ងៃ ........ ២៨

២.១.១.២. សោភ័ណភាពពេលយប់ ..... ៣០
២.១.២. ការរៀបចំសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ..... ៣០
២.១.២.១. សន្តិសុខ ..... ៣០
២.១.២.២. ភាពស្ងៀមស្ងាត់ ..... ៣៥
២.១.២.៣. បរិស្ថានក្នុងក្រុងកំពង់ចាម ..... ៣៦
**២.២. ផលវិបាកក្នុងការរៀបចំក្រុងកំពង់ចាម** ..... ៤៦
២.២.១. ធនធានមនុស្ស ..... ៤៦
២.២.២. កង្វះគម្រោងថវិកា ..... ៤៦
២.២.៣. កង្វះបច្ចេកទេស ..... ៤៧
២.២.៤. កង្វះការសហការពីប្រជាពលរដ្ឋ ..... ៤៧
**២.៣. ដំណោះស្រាយ** ..... ៤៨
២.៣.១. ដំណោះស្រាយធនធានមនុស្ស ..... ៤៨
២.៣.២. ដំណោះស្រាយគម្រោងថវិកា ..... ៤៨
២.៣.៣. ដំណោះស្រាយកង្វះបច្ចេកទេស ..... ៤៩
២.៣.៤. ដំណោះស្រាយការសហការពីប្រជាពលរដ្ឋ ..... ៥០
**សេចក្តីសន្និដ្ឋាន** ..... ៥១
**អនុសាសន៍** ..... ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនទសវត្ស ព្រះរាជាណាចក្រកម្ពុជាក៏កំពុងតែធ្វើដំណើរក្នុងការខិតខំប្រឹងប្រែងនៅក្នុងការរៀបចំសណ្តាប់ធ្នាប់នឹងធ្វើការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ដើម្បីប្រទេសជាតិមានការជឿនលឿនទៅមុខឱ្យដូចប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតនៅលើសកលលោក។ នៅក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់ទីកន្លែងមាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនានាដែលជាតម្រូវការចាំបាច់សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ។

ស្របពេលដែលប្រទេសកម្ពុជា ជាប្រទេសកំពុងតែអភិវឌ្ឍន៍នឹងត្រូវធ្វើការរៀបចំ និងអភិវឌ្ឍន៍ឱ្យបានស្របទៅតាមការកំណត់របស់ប្លង់គោល ដែលបានរៀបចំដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ហើយការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ គឺជាកត្តាមួយដ៏សំខាន់ នៅក្នុងកែលម្អឱ្យមានភាពល្អប្រសើរឡើងស្របទៅតាមប្លង់គោលស្តង់ដារបច្ចេកទេស និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺដើម្បីធ្វើយ៉ាងណាឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនានាមានសោភ័ណភាព និងសណ្តាប់ធ្នាប់ប្រកបទៅដោយភាពល្អប្រសើរជឿនលឿនទៅមុខបន្ថែមទៀត។

ដោយឡែកខេត្ត ក្រុងមួយចំនួននៅក្នុងប្រទេសកម្ពុជាក៏នៅមានភាពខ្វះចន្លោះ និងមានបញ្ហាប្រឈមជាច្រើនផងដែរ។ ដោយពេលបច្ចុប្បន្នរដ្ឋបាលខេត្ត ក្រុងកំពុងតែខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើង និងការកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យបានស្របទៅតាមប្លង់គោលស្តង់ដារបច្ចេកទេស ដើម្បីឱ្យខេត្ត ក្រុងមានសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ សុវត្ថិភាពនៃការរស់នៅ គឺសុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ។ ដោយបានមើលឃើញពីកត្តានេះហើយទើបខ្ញុំបានសម្រេចជ្រើសរើសប្រធានបទទាក់ទងនឹងនីតិនគរូបនីយកម្ម និងសំណង់ ស្តីពី **ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ឆ្នាំ២០១៨ ដល់២០២៣** ដើម្បីធ្វើការស្រាវជ្រាវបញ្ចប់ការសិក្សា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងក្រុងកំពង់ចាម គឺមានគណៈអភិបាលក្រុង និងអភិបាលរងក្រុង ជាមួយមន្ត្រីពាក់ព័ន្ធទាំងអស់ដែលមានតួនាទីក្នុងការអភិវឌ្ឍ និងរៀបចំក្រុងកំពង់ចាមឱ្យបានល្អប្រសើរ។

ទោះជាយ៉ាងនេះក្តី ដើម្បីឱ្យនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណជនបានស្វែងយល់និងធ្វើការសិក្សាស្រាវជ្រាវឱ្យមានលក្ខណៈស៊ីជម្រៅ និងមានភាពច្បាស់លាស់ទាក់ទងនឹងប្រធានបទសារណាបញ្ចប់ការសិក្សាខាងលើ ខ្ញុំបានលើកឡើងនូវចំណោទបញ្ហាមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងនោះរួមមាន៖

**១. តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំក្រុងកំពង់ចាម?**

**២. តើក្រុងកំពង់ចាមមានការអភិវឌ្ឍអ្វីខ្លះ?**

**៣. តើក្រុងកំពង់ចាមមានដំណោះស្រាយអ្វីខ្លះចំពោះការការពារបរិស្ថានឱ្យមានភាពល្អប្រសើរ?**

ដូចនេះនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណជន ប្រាកដជាបានយល់ដឹងអំពីការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ហើយស្នាដៃស្រាវជ្រាវនេះអាចយកធ្វើជាឯកសារពិគ្រោះ និងជាឯកសារជំនួញស្មារតីបានទៀតផង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺតែងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែកក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺចង់ឱ្យនិស្សិត សាធារណជន បានសិក្សាយល់ដឹងពីការអភិវឌ្ឍ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុងកំពង់ចាម។ លើសពីនេះទៀត គោលបំណងនៃការបង្កើតនូវស្នាដៃស្រាវជ្រាវនេះ ក្នុងគោលបំណងការជួយជំរុញឱ្យមានការអភិវឌ្ឍ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសនោះគឺចង់ឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់អំពីការអភិវឌ្ឍ ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ ព្រមទាំងអាចយកជាឯកសារសម្រាប់ជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងអស់ តែងតែមានដែនកំណត់របស់ខ្លួន។ ដើម្បីឆ្លើយតបទៅហ្នឹងទិដ្ឋភាពជាក់ស្តែងនៃប្រធានបទខាងលើនេះ ហើយទំហំនៃការស្រាវជ្រាវនឹងលើកយកមកបង្ហាញពីទិដ្ឋភាពនានាដែលបានពាក់ព័ន្ធជាមួយការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម។ ការអនុវត្តតាមផែនការដំណោះស្រាយរបស់អាជ្ញាធរក្រុងកំពង់ចាម។ ដូច្នេះអ្វីដែលបានទាក់ទងទៅនឹងប្រធានបទ **ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ឆ្នាំ២០១៨ ដល់២០២៣** យើងនឹងត្រូវធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលបានពាក់ព័ន្ធជាមួយនឹងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អាចចាត់ទុកបានជាការចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសង្គមកម្ពុជា ដោយបានផ្តល់នូវចំណេះដឹងចំពោះនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់អាចជួយសម្រួលដល់ការអភិវឌ្ឍ ឬរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុងកំពង់ចាម ឬយកទៅអភិវឌ្ឍន៍ក្រុងណាមួយបន្ថែមទៀត។ម្យ៉ាងទៀតដើម្បីធ្វើយ៉ាងណាឱ្យក្រុងកំពង់ចាមមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ ជាពិសេសចូលរួមចំណែកក្នុងការជំរុញឱ្យមានការអភិវឌ្ឍថ្មីៗបន្ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើការបកស្រាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា ដែលមានបញ្ហាប្រឈម និងដំណោះស្រាយរបស់អាជ្ញាធរក្រុងកំពង់ចាម ឯកសារទទួលបានពីសាលាក្រុងកំពង់ចាម សៀវភៅតែងនិពន្ធនៅក្នុងបណ្ណាល័យច្បាប់ បណ្ដាញផ្សព្វផ្សាយសង្គម ព្រមទាំងបានធ្វើការសិក្សាស្រាវជ្រាវជាមួយទិដ្ឋភាពទូទៅផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសរសេរសារណារបស់សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ខ្ញុំបានធ្វើការបែងចែករចនាសម្ព័ន្ធរបាយការណ៍ដូចខាងក្រោម៖

**ជំពូកទី១ សញ្ញាណទូទៅនៃការរៀបចំក្រុងកំពង់ចាម**

នៅក្នុងជំពូកនេះខ្ញុំនឹងបែងចែកជាបីចំណុចបន្ថែមទៀតដោយ **ចំណុចទី១** បង្ហាញអំពីសញ្ញាណទូទៅនៃការរៀបចំក្រុងកំពង់ចាម **ចំណុចទី២** បង្ហាញអំពីសមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុង និង**ចំណុចទី៣** បង្ហាញពីកត្តាដែលជំរុញឱ្យមានការរៀបចំក្រុងកំពង់ចាម។

**ជំពូកទី២ ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ក្រុងកំពង់ចាម**

នៅក្នុងជំពូកនេះដែលខ្ញុំបានបែងចែកជាបីចំណុចបន្ថែមទៀតដោយ **ចំណុចទី១** បង្ហាញអំពីការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ក្រុងកំពង់ចាម **ចំណុចទី២** បង្ហាញអំពីផលវិបាកក្នុងការរៀបចំក្រុងកំពង់ចាម និង**ចំណុចទី៣** បង្ហាញអំពីដំណោះស្រាយ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការរៀបចំ
# ក្រុងកំពង់ចាម

# ជំពូកទី១
# សញ្ញាណទូទៅនៃការរៀបចំក្រុងកំពង់ចាម

យោងទៅតាមភាពជាក់ស្តែងក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់របស់ក្រុងកំពង់ចាមនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សង្កេតឃើញថាក្រុងកំពង់ចាមបានរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់បានយ៉ាងល្អប្រសើរ។ ដោយក្នុងការប្រឡងប្រណាំងទីក្រុងស្អាតលើកទី៣ ក្រុងកំពង់ចាមបានទទួលជ័យលាភីផ្កាវិដ្ឋូល៣ទង។ នេះដោយសារតែរដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធទាំងអស់មានការយកចិត្តទុកដាក់ជាខ្លាំងទៅលើការរៀបចំសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ សុខសុវត្ថិភាព និងគិតពីសុខមាលភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុង។ ក្នុងនោះរដ្ឋបាលក្រុងបានយកចិត្តទុកដាក់រៀបចំជួសជុលកែលម្អផ្លូវ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមក្នុងក្រុងដូចជា សាងសង់ផ្លូវក្រាលកៅស៊ូ ផ្លូវបេតុង ដាក់លូ ដាក់ភ្លើងនៅតាមដងផ្លូវ ដាំដើមឈើ និងសួនច្បារជាដើម។ ទោះបីជានៅក្នុងគម្រោងខ្លះនៅសេសសល់ដែលរដ្ឋបាលក្រុងអនុវត្តន៍ពុំទាន់មានប្រសិទ្ធិភាព និងមិនទាន់មានការផ្លាស់ប្តូរក៏ដោយក្តី រដ្ឋបាលក្រុងបានខិតខំបន្តជំរុញការកែលម្អ ដើម្បីធានាឱ្យបាននូវលទ្ធផលល្អប្រសើរបន្ថែមទៀត។ តាមរយៈការចូលរួមសហការពីប្រជាពលរដ្ឋ រួមជាមួយនឹងមន្ត្រីជំនាញដែលពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់បានជំរុញឱ្យក្រុងកំពង់ចាមមានការអភិវឌ្ឍជាបន្តបន្ទាប់ ដោយបានរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានតែប្រសើរ និងរីកចម្រើនបន្ថែមទៀត។

## ១.១. ទិដ្ឋភាពទូទៅ

### ១.១.១. ទីតាំងភូមិសាស្ត្រ

ខេត្តកំពង់ចាម ជាខេត្តមួយស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តត្បូងឃ្មុំ ខាងលិចជាប់នឹងខេត្តកំពង់ឆ្នាំង ខាងត្បូងជាប់នឹងខេត្តកណ្តាល និងខេត្តព្រៃវែង ខាងជើងជាប់នឹងខេត្តក្រចេះ និងខេត្តកំពងធំ។ ខេត្តកំពង់ចាម មានចម្ងាយ ១២៤គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដោយឆ្លងកាត់តាមផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៧ ដែលមានផ្ទៃដីសរុបចំនួន ៤៥៤៨,០៩គីឡូម៉ែត្រការ៉េ និងមានក្រុង១ និងស្រុក៩ គឺក្រុងកំពង់ចាម ស្រុកកំពង់សៀម ស្រុកស្ទឹងត្រង់ ស្រុកចម្ការលើ ស្រុកព្រៃឈរ ស្រុកជើងព្រៃ ស្រុកបាធាយ ស្រុកកងមាស ស្រុកកោះសូទិន និងស្រុកស្រីសន្ធរ។ ខេត្តកំពង់ចាម មានសង្កាត់ចំនួន ០៤ ឃុំចំនួន ១០៥ ភូមិចំនួន ៩២៣ និងប្រជាពលរដ្ឋសរុបចំនួន ២៨៤,៣៨៩គ្រួសារ ស្មើនឹង ១,១១៥,៥៨៥នាក់ ក្នុងនោះមានស្ត្រីចំនួន ៥៧៥,៣៥៨នាក់ ដែលមានដង់ស៊ីតេ ២៤៥នាក់/មួយគីឡូម៉ែត្រការ៉េ។[១]

[១] របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ឆ្នាំ២០១៨-២០២២ ទំព័រទី៦២០-៦២១

ខេត្តកំពង់ចាម ជាផ្លូវការត្រូវបានបែងចែកជាពីរ គឺខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលផ្ទៃដីខាងកើតទន្លេមេគង្គ គឺជាខេត្តត្បូងឃ្មុំ ដោយបានកាត់យកក្រុងចំនួន ០១ ស្រុកចំនួន ០៦ ពីខេត្តកំពង់ចាមរួមមាន ក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកមេមត់។[២]

ដោយឡែកក្រុងកំពង់ចាម គឺជាទីប្រជុំជន និងជាក្រុងតែមួយគត់ក្នុងចំណោមក្រុងស្រុកទាំង១០ នៃខេត្តកំពង់ចាម។ ក្រុងកំពង់ចាម ស្ថិតនៅក្នុងភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ដែលមានព្រំប្រទល់ ខាងលិចជាប់នឹងស្រុកកំពង់សៀម ខាងកើតជាប់នឹងខេត្តត្បូងឃ្មុំ ខាងជើងជាប់នឹងស្រុកកំពង់សៀម និងខាង ត្បូងជាប់នឹងស្រុកកំពង់សៀម។ ក្រុងកំពង់ចាម មានផ្ទៃដីសរុប ២២,១៥គីឡូម៉ែត្រការ៉េ សង្កាត់ចែកចេញជា ៤សង្កាត់ ភូមិមានចំនួន ៣២ភូមិ។[៣]

### ១.១.២. ស្ថានភាពប្រជាសាស្ត្រ

ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងកំពង់ចាមមានប្រជាជនសរុបចំនួន ៤៤,៣១១នាក់ ក្នុងមានស្ត្រីចំនួន ២២,៩២៥នាក់ និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមានចំនួន ៣២,៧៦០នាក់ ក្នុងនោះស្ត្រី មានចំនួន ១៧,២៦៧នាក់។ គ្រួសារសរុបចំនួន ៩,៨០១គ្រួសារ គ្រួសារដែលរស់នៅជាអចិន្ត្រៃយ៍ចំនួន ៩,៥៥២ គ្រួសារ និងគ្រួសារដែលរស់នៅបណ្តោះអាសន្នមានចំនួន ២៤៩គ្រួសារ។[៤]

ដោយក្រុងកំពង់ចាម ជាក្រុងតែមួយគត់ក្នុងចំណោមក្រុងស្រុកទាំង ១០នៃខេត្តកំពង់ចាម ជីវភាពនៃ ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងក្រុងកំពង់ចាម ដោយប្រកបមុខរបររកស៊ីចិញ្ចឹមជីវិតទៅតាមប្រភេទផ្សេងៗគ្នា ដែលមានដូចជា ការប្រកបមុខរបរអាជីវកម្ម និងសិប្បកម្មជាដើម ដែលជាមូលដ្ឋានក្នុងការបង្កើនសេដ្ឋកិច្ច គ្រួសារ និងជួយបង្កើនសេដ្ឋកិច្ចជាតិឱ្យបានកាន់តែរីកចម្រើនផងដែរ។ ហើយប្រជាពលរដ្ឋមួយចំនួនក៏ប្រកប មុខរបរកសិកម្ម និងចិញ្ចឹមសត្វដែលជាចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ និងជាកត្តាចំណូលរបស់ក្រុងផងដែរ។

- **អាជីវកម្ម**

ប្រជាពលរដ្ឋប្រកបមុខរបរអាជីវកម្មនៅក្នុងក្រុងកំពង់ចាមមានទៅតាមប្រភេទផ្សេងៗគ្នា ដោយមុខរបរ ចម្បងក្នុងការប្រកបមុខរបរអាជីវកម្មមានដូចជា ផ្នែកសិប្បកម្ម និងផ្នែកសេវាកម្ម ដែលមានទីតាំងសរុបចំនួន ៣៨៧កន្លែង ដែលក្នុងនោះរួមមាន៖ ការ៉ាស់សាំង ១៩កន្លែង សណ្ឋាគារ ១៧កន្លែង អាហារដ្ឋាន ១១២កន្លែង

[២] ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ, ៣១ ធ្នូ ២០១៣, មាត្រា១

[៣] របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងកំពង់ចាម, លេខ០០១/២៣ រ.ប.ក, ប្រចាំឆ្នាំ២០២២

[៤] របាយការណ៍ស្តីពីការិយាល័យផែនការ និងគាំទ្រសង្កាត់, លេខ០៤៣ ផ.ក.ក្រក.ច, ប្រចាំឆ្នាំ២០២២

អាជីវកម្មលក់គ្រឿងសង្ហារឹម ៣៤កន្លែង ក្រុមហ៊ុន ១៤កន្លែង គ្រឹះស្ថានហិរញ្ញវត្ថុ ១៦កន្លែង ធនាគារ ១៧កន្លែង ផ្ទះសំណាក់ ៤៨កន្លែង អាជីវកម្មផ្សារដែក និងឡតដ្ឋ ៨០កន្លែង និងសិប្បកម្មផ្សេងៗទៀតចំនួន ៣០កន្លែង។[៥]

❖ **កសិកម្ម**

ក្រៅពីការងារប្រកបមុខរបរអាជីវកម្ម ប្រជាពលរដ្ឋរស់នៅក្នុងក្រុងកំពង់ចាមក៏បានប្រកបមុខរបរចិញ្ចឹមជីវិតដោយបានពឹងផ្អែកទៅលើវិស័យកសិកម្ម និងដំណាំរួមផ្សំផងដែរ។ ដោយក្រុងកំពង់ចាមមានផ្ទៃដីសរុប ២២១៥ហិកតា ស្មើនឹង ២២,១៥គីឡូម៉ែត្រការ៉េ នៅក្នុងនោះមានផ្ទៃដីបង្កបង្កើនផលស្រូវវស្សា ១១៩ហិកតា ស្មើនឹង ១,១៩គីឡូម៉ែត្រការ៉េ ដោយទទួលបានទិន្នផលជាមធ្យម ២,៥តោន/១ហិកតា និងផ្ទៃដីបង្កបង្កើនផលស្រូវប្រាំង ២៣ហិកតា ស្មើនឹង ០,២៣គីឡូម៉ែត្រការ៉េ ទទួលបានទិន្នផលជាមធ្យម ២,៣តោន/១ហិកតា។ ក្រៅពីការធ្វើស្រែចម្ការ និងដំណាំរួមផ្សំ ប្រជាពលរដ្ឋក៏បានចិញ្ចឹមសត្វក្នុងនោះមានដូចជា ចិញ្ចឹមគោ ក្របី មាន់ ទា ជ្រូក ចៀម ពពែ សេះ ត្រីជាដើម។[៦]

## ១.២. សមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុង

ជាទូទៅការរៀបចំក្រុងមួយ ដែលប្រកបទៅដោយសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងគ្មានការបំពុលបរិស្ថានទាំងប្រាំនៅក្នុងក្រុង។ ជាការចាំបាច់ត្រូវតែមានគម្រោងផែនការអភិវឌ្ឍន៍ និងជាកម្មវិធីវិនិយោគមួយឱ្យបានត្រឹមត្រូវជាមុនសិន ទើបការអភិវឌ្ឍក្រុងនោះទទួលបានភាពល្អប្រសើរ និងប្រកបដោយប្រសិទ្ធិភាព។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដែលជាតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមធ្យោបាយត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការមូលដ្ឋាន។ ដើម្បីដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធិភាព និងសម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ការកសាង ការអនុម័ត ការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ត្រូវធ្វើឡើងដោយមានការចូលរួមសហការពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ ជាពិសេសគឺរដ្ឋបាលក្រុង។

### ១.២.១. សមាសភាព

សមត្ថកិច្ចសំខាន់ៗដែលពាក់ព័ន្ធ ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ គឺរដ្ឋបាលក្រុង ដែលក្នុងនោះមានក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង រួមជាមួយមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។ ដោយយោងតាមអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងបានកំណត់រចនាសម្ព័ន្ធរដ្ឋបាលក្រុងដូចខាងក្រោម៖

[៥] របាយការណ៍ស្តីពីការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ក្រុងកំពង់ចាម, ប្រចាំឆ្នាំ២០២០

[៦] សៀវភៅ ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០២០-២០២៤) ក្រុងកំពង់ចាម




### ១.២.១.១. ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាក្រុងត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោត ស្របតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សាក្រុង គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[៧] ក្រុមប្រឹក្សាក្រុង មានអាណត្តិប្រាំ (៥) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ជាក់ស្ដែងសមាជិកក្រុមប្រឹក្សាក្រុងកំពង់ចាមសម្រាប់អាណត្តិទី៣មានចំនួន ១៧នាក់ ក្នុងនោះមាន ១រូបជាប្រធានក្រុមប្រឹក្សា និង ១៦រូប ជាសមាជិកក្រុមប្រឹក្សា។[៨]

[៧] អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៦១

[៨] អនុក្រឹត្យស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣, លេខ២២ អនក្រ.បក, ២៥ មករា ២០១៩, មាត្រា២

យោងតាមអនុក្រឹត្យលេខ២១៦ អនប្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៧៥ កថាខណ្ឌទី១ គឺក្រុមប្រឹក្សាក្រុង ត្រូវបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី (៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

### ក. កិច្ចប្រជុំក្រុមប្រឹក្សាក្រុង

កិច្ចប្រជុំក្រុមប្រឹក្សាមានពីរ គឺកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ កិច្ចប្រជុំក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬលើកលែងតែរបៀបវារៈនៃកិច្ចប្រជុំរបស់ខ្លួនបានតម្រូវឱ្យពិភាក្សាជាសម្ងាត់ប៉ុណ្ណោះ។ ក្រុមប្រឹក្សា ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួនឱ្យបានទៀងទាត់ យ៉ាងហោចណាស់ចំនួន ១២ដងក្នុងមួយឆ្នាំទៅតាមប្រតិទិន ដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញរបស់ខ្លួនបានទៅតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ។ តាមការស្នើរបស់ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សា ១/៣ នៃចំនួនក្រុមប្រឹក្សាទាំងមូល ឬអភិបាល ឬគណៈអភិបាល។

ដោយយោងតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦៧ កថាខណ្ឌទី១ គឺកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដែលអាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

### ខ. សិទ្ធិអំណាចក្រុមប្រឹក្សាក្រុង

ដោយយោងតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦៦ ក្រុមប្រឹក្សាក្រុង មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីការបស់ខ្លួន និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនានា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ហើយត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តន៍ដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។ ដោយយោងតាមអនុក្រឹត្យលេខ២១៦ ដដែលនេះ មាត្រា៧២ កថាខណ្ឌទី១ ក្រុមប្រឹក្សាក្រុង ត្រូវបានប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

### ១.២.១.២. គណៈអភិបាលក្រុង

សាលាក្រុងនីមួយៗ ត្រូវតែមានគណៈអភិបាលក្រុង ដែលនៅក្នុងនោះរួមមានអភិបាលក្រុងចំនួន ០១រូប និងអភិបាលរងក្រុងមួយចំនួនដែលត្រូវបានតែងតាំងឡើង ដោយស្របទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៩] ជាក់ស្តែងអភិបាល នៃគណៈអភិបាលក្រុងកំពង់ចាមមានចំនួន ០៧រូប ក្នុងនោះមានចំនួន ០១រូបជាអភិបាលក្រុង និងចំនួន ០៦រូបជាអភិបាលរងក្រុង។[១០]

**សម្គាល់៖** អភិបាលក្រុង និងអភិបាលរងក្រុង មិនមែនជាក្រុមប្រឹក្សាក្រុងឡើយ។

- **កិច្ចប្រជុំគណៈអភិបាលក្រុង**

កិច្ចប្រជុំរវាងអភិបាល និងអភិបាលរងនៅក្នុងគណៈអភិបាលរបស់ខ្លួន។ គណៈអភិបាលត្រូវជួបប្រជុំគ្នាជាទៀងទាត់ប្រចាំអឌ្ឍមាស។ ក្រៅពីប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលជួបប្រជុំតាមការចាំបាច់ទៅតាមសំណើរបស់អភិបាល។ កិច្ចប្រជុំអាចដំណើរការទៅបានលុះត្រាតែសំឡេងអភិបាល អភិបាលរងបានលើសពាក់កណ្តាលនៃសមាសភាពគណៈអភិបាលទាំងមូល។ សេចក្តីសម្រេចនៃកិច្ចប្រជុំគណៈអភិបាលដែលអាចយកជាការបាន គឺលុះត្រាតែសំឡេងអនុម័ត បានលើសពីពាក់កណ្តាលនៃចំនួនសមាសភាពរបស់គណៈអភិបាលទាំងមូល ប៉ុន្តែប្រសិនបើនៅក្នុងករណីមានចំនួនសំឡេងស្មើគ្នា គឺត្រូវយកសំឡេងអធិបតីរបស់អង្គប្រជុំមានឧត្តមានុភាព។

អភិបាល គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ ក្នុងករណីអភិបាលអវត្តមាន អភិបាលស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ ហើយគ្រប់កិច្ចប្រជុំរបស់គណៈអភិបាល ត្រូវតែមានកំណត់ហេតុ ដែលរៀបចំឡើងដោយនាយករដ្ឋបាល និងត្រូវមានហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

### ១.២.២. តួនាទី និងភារកិច្ច

ជាការពិតមុខតំណែងនីមួយៗ គឺជាតួនាទី និងភារកិច្ចដែលត្រូវបានបែងចែក ដើម្បីបម្រើប្រជាពលរដ្ឋ និងដំណើរការនៃការងារកុំឱ្យមានបញ្ហាកកស្ទះ ហើយដើម្បីរៀបចំទីក្រុងមួយ ទាល់តែមានការចូលរួមចាត់ចែងពីរដ្ឋបាលក្រុងនីមួយៗផងដែរ។

[៩] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៨២

[១០] អនុក្រឹត្យស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ, លេខ១១៩ អនក្រ.បក, ១៧ មិថុនា ២០១៧, មាត្រា២

### ១.២.២.១. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង

តួនាទី និងភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាក្រុង មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុងលើកំណត់ហេតុ និងឯកសារមួយចំនួនដូចជា៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុង តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាក្រុង ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែង ដោយផ្អែកតាមករណីមួយចំនួនដូចជា៖
  - បាត់បង់លក្ខណៈសម្បត្តិជាអភិបាល ឬអភិបាលរង
  - អសមត្ថភាព
  - បំពេញការងារមិនបានល្អ
  - មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
  - បោះបង់ចោលការងារ
  - និងប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងរយៈពេលដប់ពីរ (១២) ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[១១]

**ក. ចំពោះភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង**

- ណែនាំផ្នែកគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង

[១១] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៦៩ កថាខណ្ឌទី១

- តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ក្រុង
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ និងអនុម័តសំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង នៅក្នុងករណីចាំបាច់។[១២]

**ខ. របៀបរបបការងារ និងការប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង**

- ក្រុមប្រឹក្សាក្រុង ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តន៍ ដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។
- ក្រុមប្រឹក្សាក្រុង អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ នៅក្នុងករណីនេះ គណៈអភិបាលក្រុង ត្រូវដឹកនាំនាយករដ្ឋបាលសាលាក្រុង និងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។
- ក្រុមប្រឹក្សាក្រុង ត្រូវឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយដែលក្នុងក្រុមប្រឹក្សាក្រុងបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព។
- ក្នុងករណី កិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត មិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាព ដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ។

[១២] សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង, ០២ មីនា ២០១៧, ទំព័រទី២

➢ ក្នុងករណី កិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនសមស្រប និងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តន៍បាន ក្រុមប្រឹក្សាក្រុងត្រូវចាត់តាំងឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃ គ.ជ.អ.ប. ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។[១៣]

**បញ្ជាក់៖** ក្រុមប្រឹក្សាខេត្តត្រូវមានតួនាទីក្នុងការប្រតិភូកម្មអំណាចក្នុងនាមជាអ្នកតំណាងរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ និងត្រួតពិនិត្យនីត្យានុកូលភាពទៅលើសេចក្តីសម្រេចនឹងសកម្មភាពរបស់រដ្ឋបាលក្រុង ដើម្បីធានាថារដ្ឋបាលក្រុង បានបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់ជាតិ។ ការធ្វើប្រតិភូកម្មនេះរួមមានដូចខាងក្រោម៖

➢ ការវាយតម្លៃ និងរៀបចំយុទ្ធសាស្ត្រសមស្របផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាក្រុងព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាទាំងអស់

➢ ការណែនាំ និងសម្របសម្រួល គាំទ្រដល់ក្រុមប្រឹក្សាក្រុង ក្នុងការអនុវត្តការងារ ភារកិច្ច និងធនធានដែលបានប្រគល់ឱ្យស្របទៅតាមច្បាប់ លិខិបទដ្ឋានគតិយុត្ត និងគោលនយោបាយរបស់ជាតិ និងត្រូវធានាថាអភិបាលក្រុង បានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់នៅក្នុងក្រុង

ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ក្រុង និងសង្កាត់ ឱ្យស្រមតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យនេះ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រចរបស់ គ.ជ.អ.ប.។ ក្រុមប្រឹក្សាខេត្ត ត្រូវធ្វើប្រតិភូកម្មអំពីការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់គណៈអភិបាលខេត្ត ដើម្បីអនុវត្តន៍កិច្ចការប្រចាំថ្ងៃ ហើយការអនុវត្តការងារប្រចាំថ្ងៃគណៈអភិបាលជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរដ្ឋាភិបាល ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាលជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ព្រមទាំងគាំទ្រដល់ រដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត។ គណៈអភិបាលត្រូវស្នើសុំគោលការណ៍ណែនាំ និងធ្វើសេចក្តីរាយការណ៍អំពីការអនុវត្តតួនាទី ភារកិច្ចខាងលើនេះរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សារបស់ខ្លួន ហើយ

[១៣] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៦៦ មាត្រា៦៨ កថាខណ្ឌទី១ កថាខណ្ឌទី៤ មាត្រា៧២ កថាខណ្ឌទី២ កថាខណ្ឌទី៣

នៅក្នុងករណីចាំបាច់ ក្រុមប្រឹក្សាខេត្តអាចកោះប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ ពិភាក្សាអំពីការគាំទ្រ ការធ្វើប្រតិភូកម្មខាងលើនេះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប. និងត្រូវចេញប្រកាសដើម្បីកំណត់អំពីគោលការណ៍ និងនីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មនេះ។[១៤]

### គ. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុងមានពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាក្រុងអាចប្រជុំសាមញ្ញយ៉ាងហោចណាស់ ១២/១ឆ្នាំ និងប្រជុំវិសាមញ្ញ ក្រុមប្រឹក្សាក្រុង អាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ។ កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបានលុះត្រាតែកិច្ចប្រជុំទាំងនេះ ប្រព្រឹត្តទៅត្រឹមត្រូវ ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង។ សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើង មិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះ ពុំមានសុពលភាពទេ។

រាល់កិច្ចប្រជុំរបស់ខ្លួនក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍គោលនយោបាយរបស់រដ្ឋបាលក្រុង និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាក្រុងប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងជាមួយដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង

[១៤] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា១៩៦

- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។[១៥]

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុងត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំ ដែលបានរៀបរាប់ខាងលើនេះ ក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួន នូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធទាំងមូលមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ឬហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើការអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលក្រុងអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការអង្កេតនោះ
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃក្នុងករណីដូចជា៖
    - ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវរាយការណ៍លាយលក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

[១៥] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៧០

- ក្នុងករណីការប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬធ្វើទុកបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈណាមួយ
- ក្នុងករណីការមិនបានប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះ ដែលបានកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈ
- ការរំលោភសិទ្ធិស្របច្បាប់ ឬសិទ្ធិមនុស្សរបស់ជនណាម្នាក់
- ការកាន់កាប់ ឬការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់
- ការធ្វើអន្តរាយដល់បរិស្ថាន ធនធានធម្មជាតិ
- ការដកយកថវិកា ឬទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ
- ការស្នើសុំ ឬការទទួលប្រាក់ ឬរង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬមិនធ្វើកិច្ចការណាមួយ ដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬរង្វាន់ នោះមិនបានកំណត់នៅក្នុងច្បាប់
- ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស
- ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា
- ការធ្វើសេចក្តីសម្រេចនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍គ្រួសាររបស់ខ្លួន។[១៦]

➢ ពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង

➢ ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន

➢ ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

➢ ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ រៀបចំដោយគណៈអភិបាលក្រុង

---

[១៦] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២២ ឧសភា ២០០៨, មាត្រា៤៧, ៤៨, ៤៩

- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។[១៧]

### ១.២.២.២. តួនាទី និងភារកិច្ចរបស់គណៈអភិបាលក្រុង

**ក. គណៈអភិបាលក្រុងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុង
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង៖
    - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាពលទ្ធផលនៃការអនុវត្ត
    - របាយការណ៍ហិរញ្ញវត្ថុ

[១៧] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៧១

- ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិក
- វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
- កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

➢ របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស

➢ ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង

➢ ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

➢ ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់

➢ ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់

➢ កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន។[១៨]

**ខ. គណៈអភិបាលក្រុងក្នុងតួនាទី ជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល**

នៅក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង អភិបាលក្រុងមានភារកិច្ចដូចខាងក្រោម៖

➢ ណែនាំដល់ការិយាល័យ អង្គភាព ទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្រុងឱ្យអនុវត្តន៍តួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។

➢ សម្របសម្រួលទិសដៅដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាពទីភ្នាក់ងារ

[១៨] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៨៦

ពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តន៍កិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួល តម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុង ក្នុងការធ្វើសមាហរណកម្មផែនការថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង។

- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់។
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅក្នុងក្រុងរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះអភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួន ករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលខេត្ត។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពសាមីប្រចាំនៅខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុងដែលពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី។
- អភិបាលក្រុងមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។[១៩]
- អភិបាលក្រុងត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ

[១៩] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៩២ កថាខណ្ឌទី១

ក្នុងក្រុង អំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងក្រុង។ អភិបាលក្រុង គឺជាប្រធានគណៈបញ្ជាការឯកភាពក្រុងក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធ និងសង្កាត់ក្នុងក្រុង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងក្រុង។[២០]

យោងតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៩២ កថាខណ្ឌទី២ ដើម្បីធានាឱ្យអភិបាលក្រុងធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល និងអនុវត្តនូវភារកិច្ចខាងលើនេះ ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំក្រុង ត្រូវដាក់ជូនអភិបាលក្រុងដើម្បីពិនិត្យ និងផ្តល់យោបល់។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុង ត្រូវចុះហត្ថលេខាខាងលើរបាយការណ៍នោះរួមជាមួយនឹងប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រុង ស្ថាប័នដែលប្រចាំនៅក្នុងក្រុង ត្រូវចម្លងជូនសាលាក្រុង។

**គ. របៀបរបបការងារនៃគណៈអភិបាលក្រុង**

នៅក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន គណៈអភិបាលក្រុង អភិបាលក្រុង ឬអភិបាលរងក្រុងត្រូវពិនិត្យនូវចំណុចមួយចំនួន ដែលបានពាក់ព័ន្ធនឹងរបៀបរបបក្នុងការអនុវត្តការងារមានដូចខាងក្រោម៖

- នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ស្ថាប័ននានាស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា។
- នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាជាចាំបាច់ អភិបាលក្រុង ត្រូវយកការងារទាំងនោះមកពិគ្រោះក្នុងគណៈអភិបាលក្រុងរបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។
- អភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាក្រុង អំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន ហើយអភិបាលរងក្រុងត្រូវទទួលខុសត្រូវចំពោះអភិបាលក្រុងលើភារកិច្ច

[២០] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៩៣

នានាដែលអភិបាលក្រុងបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

- ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស និងការប្រជុំអឌ្ឍមាសទី២ នៃខែនីមួយៗជាការប្រជុំប្រចាំខែ។ ក្រៅពីប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំខាងលើ គណៈអភិបាលក្រុងអាចកោះប្រជុំតាមការចាំបាច់។ រៀងរាល់កិច្ចប្រជុំខាងលើនេះត្រូវមានកំណត់ហេតុ។
- គណៈអភិបាលក្រុង ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុង និងអភិបាលរងក្រុង និងសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន ហើយអភិបាលក្រុង ត្រូវទទួលបែងចែកភារកិច្ចនេះ និងត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។
- អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានគតិយុត្តដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខា។ អភិបាលក្រុង អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងក្នុងការចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។ អភិបាលក្រុងត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទនីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង។
- អភិបាលក្រុង មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយ ដែលបានប្រើប្រាស់អំណាចមិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី ហើយការប្រគល់ និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។
- ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី។ ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងក្រុង ស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរង នៃគណៈអភិបាលក្រុង ត្រូវធ្វើជាអភិបាលក្រុងស្តីទី។
- ក្នុងករណីអភិបាលក្រុងស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលក្រុងស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តន៍ជូនអភិបាលក្រុង នៅពេលអភិបាលក្រុងមានវត្តមានវិញ។

- គណៈអភិបាលក្រុង អភិបាលក្រុង អភិបាលរងក្រុង ដែលបានសម្រេច ឬដែលបានអនុវត្តន៍កិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេចនេះ ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលក្រុង អភិបាលក្រុង អភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ពីការសម្រេច ឬសកម្មភាពខាងលើនេះ។[២១]

### ឃ. ភារកិច្ចរបស់គណៈអភិបាលក្រុង ក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង

- ដឹកនាំសម្របសម្រួលការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ស្របតាមការណែនាំរបស់ក្រុមប្រឹក្សាក្រុង
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ ផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍មុនដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត
- ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង
- ដាក់សំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុងជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត
- ដឹកនាំ និងសម្របសម្រួលការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង តាមការណែនាំរបស់ក្រុមប្រឹក្សា។[២២]

### ង. ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាក្រុងបានសម្រេចរួចគណៈអភិបាលក្រុង ត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តន៍ក្នុងនាមក្រុមប្រឹក្សាក្រុងរបស់ខ្លួន។ ដូច្នេះគណៈអភិបាលក្រុង គឺជាអ្នកអនុវត្តន៍សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាក្រុង ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តន៍ដោយគណៈអភិបាលក្រុង ដើម្បីធានាថាគណៈអភិបាលក្រុងអនុវត្តន៍កិច្ចការទាំងនោះ បានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាក្រុង
- គណៈអភិបាលក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង

---

[២១] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៩៥, ៨៨, ៩០, ៩១, ៩៧, ៨៩

[២២] សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង, ០២ មីនា ២០១៧, ទំព័រទី២

- គណៈអភិបាលក្រុង ត្រូវមានគណេយ្យភាពចំពោះក្រុមប្រឹក្សាក្រុងរបស់ខ្លួន ពីការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង និងមានគណេយ្យភាពចំពោះរដ្ឋាភិបាល អំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា
- អភិបាលក្រុង ដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវរៀបចំសេចក្ដីរាយការណ៍អំពីសកម្មភាព លទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន
- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលក្រុង ក្នុងនាមតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងអាចតម្រូវឱ្យអភិបាលក្រុងធ្វើសេចក្ដីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាក្រុង អាចផ្ដល់អនុសាសន៍ និងការណែនាំដល់អភិបាលក្រុង អំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលក្រុងត្រូវទទួលយកអនុសាសន៍ និងការណែនាំពីក្រុមប្រឹក្សាក្រុងរបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅក្រុងក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួនវិញ។[២៣]

## ១.៣. កត្តាជំរុញឱ្យមានការរៀបចំក្រុង

ជាការពិតណាស់ នៅក្នុងការរៀបចំក្រុងមួយត្រូវបានធ្វើឡើង ជាចាំបាច់ត្រូវការគិតគូរឱ្យបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ។ មុនឈានទៅដល់ការរៀបចំក្រុង ឬអភិវឌ្ឍន៍អ្វីមួយ មិនមែនកើតឡើងដោយសារតែភាពចៃដន្យនោះទេ គឺវាបណ្ដាលមកពីភាពខ្វះចន្លោះ ដែលជាហេតុនាំឱ្យកើតមានឡើងនៅបញ្ហាផ្សេងៗ។ ហើយការមានភាពខ្វះចន្លោះ ឬបានលេចឡើងនូវបញ្ហាផ្សេងៗ ឬមានការខ្វះខាត ហើយបញ្ហាទាំងអស់នេះជាតម្រូវការឱ្យធ្វើការកែប្រែ និងរៀបចំក្រុងជាចាំបាច់។ យ៉ាងណាមិញយើងក្រឡេកមើលតាមតំបន់នានាដូចជា ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង តែងតែមានការរៀបចំគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍន៍នៅតាមតំបន់នានា ដែលកំពុងជួបនូវបញ្ហា ដែលនឹងត្រូវរៀបចំឱ្យមានភាពល្អប្រសើរឡើងជាងមុន។

[២៣] អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦ អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៧៣, ៨៤, ៩៦

ចំពោះក្រុងកំពង់ចាម ដោយសារសង្កេតឃើញពីភាពខ្វះចន្លោះ និងមានបញ្ហាជាច្រើនបានកើតមានឡើងនៅក្នុងក្រុងរបស់ខ្លួន ក្រុងកំពង់ចាមក៏បានយកចិត្តទុកដាក់ធ្វើការរៀបចំកែលម្អដោយមានការគិតគូរបានយ៉ាងល្អ ហើយបញ្ហាដែលនាំឱ្យមានការរៀបចំរួមមាន៖

### ១.៣.១. កំណើនប្រជាជន

ជាទូទៅការកើនឡើងនៃចំនួនប្រជាជននៅក្នុងក្រុងមានកត្តា៣សំខាន់ៗគឺ កំណើនប្រជាជននៅក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនប្រជាជនកើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់ទាំងនោះជាទីជនបទ។ កំណើនប្រជាជនដែលរស់នៅក្នុងក្រុងជាលក្ខណៈធម្មជាតិ ពីមួយឆ្នាំទៅមួយឆ្នាំប្រជាជនចេះតែកើនឡើង ដូច្នេះអត្រាកើនឡើងនៃកំណើនប្រជាជនថ្មីនៅក្នុងក្រុង ដោយស្ថិតទៅតាមកាលៈទេសៈពេលវេលាចេះតែទៅមុខ អត្រាមរណៈភាពតិចអត្រាកំណើតក៏ច្រើនផងដែរ។ ការកើនឡើងនៃចំនួនប្រជាជនដោយសារការចំណាកស្រុកពីជនបទមកកាន់ក្រុងគឺដោយសារតែក្រុងជាទីកន្លែងពាណិជ្ជកម្ម ឧស្សាហកម្ម និងសេវាកម្មផ្សេងៗ ដែលប្រមូលផ្តុំទៅដោយ រោងចក្រសហគ្រាស ពីព្រោះក្រុងជាកន្លែងប្រមូលមុំការងារ ទើបធ្វើឱ្យប្រជាជននៅជនបទធ្វើចំណាកស្រុកមកកាន់ក្រុងដើម្បីស្វែងរកការងារធ្វើ និងផ្គត់ផ្គង់ជីវភាព។ ហើយកំណើនប្រជាជនដោយសារការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់ទាំងនោះជាទីជនបទ គឺកើតឡើងដោយសារសណ្ឋានដីក្រុងថ្មីដែលពីមុនជាខេត្ត ឬស្រុក។[២៤]

**កំណើនប្រជាជនកម្ពុជា** យោងតាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៩ បង្ហាញថាប្រជាជនសរុបមានចំនួន ១៥.៥៥២.២១១នាក់ បានកើនឡើងពី ១៣.៣៩៥.៦៨២នាក់ក្នុងឆ្នាំ២០០៨។ ចំនួនប្រជាជនសរុបបានកើនឡើង ២.១៥៦.៥២៩ ត្រូវជា ១៦,១(%)ភាគរយ នៅក្នុងរយៈពេល ១១ឆ្នាំ គឺចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។ ចំនួនមនុស្សប្រុសមាន ៧.៥៧១.៨៣៧នាក់ ស្មើនឹង ៤៨,៧(%)ភាគរយនៃចំនួនប្រជាជនសរុប ខណៈពេលដែលចំនួនស្ត្រីមាន ៧.៩៨០.៣៧៤នាក់ ស្មើនឹង ៥១,៣(%)ភាគរយនៃចំនួនប្រជាជនសរុប។

ជំរឿនលើកដំបូងរបស់ប្រទេសកម្ពុជាត្រូវបានដំណើរការ បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីការគ្រប់គ្រងរបស់បារាំងនៅឆ្នាំ១៩៦២ ដែលប្រជាជនកម្ពុជានៅពេលនោះមានតែ ៥,៧លាននាក់។ ដោយតាមទម្រង់ប្រជសាស្ត្រប្រទេសកម្ពុជាបានផ្លាស់ប្តូរទាំងស្រុងបន្ទាប់ពីជំរឿនលើកដំបូងដោយសារសង្គ្រាម និងភាពចលាចល។ ក្រោយឆ្នាំ១៩៦២ ដោយប្រទេសកម្ពុជាខកខានធ្វើជំរឿនរហូតដល់ឆ្នាំ១៩៩៨។ ទោះជាយ៉ាងណាក៏ដោយមានការប៉ាន់ស្មានចំនួនប្រជាជនដោយអ្នកជំនាញផ្នែកប្រជាសាស្ត្រ ការអង្កេតប្រជាសាស្ត្រឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨០ បាន

[២៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៦-១៧

ប៉ាន់ស្មានប្រជាជនកម្ពុជាប្រមាណ ៦,៦លាននាក់។ ក្រោយមកវិទ្យាស្ថានជាតិស្ថិតិបានដឹកនាំអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៤ បានប៉ាន់ស្មានប្រជាជនរបស់ប្រទេសចំនួន ៩,៩លាននាក់។ ដោយឡែកវិទ្យាស្ថានស្ថិតិបានធ្វើអង្កេតប្រជាសាស្ត្រនៅខែមីនា ឆ្នាំ១៩៩៦ បានគ្រប់ដណ្ដប់លើគ្រួសារចំនួន ២០.០០០គ្រួសារ ចំនួនប្រជាជនប៉ាន់ស្មានមាន ១០,៧លាននាក់។ ចំនួនប្រជាជនកម្ពុជាសរុប ផ្អែកតាមជំរឿនខែមីនា ឆ្នាំ១៩៩៨ មានចំនួន ១១,៤លាននាក់ ប្រទេសកម្ពុជាបានធ្វើអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៤ ប្រជាជនកម្ពុជាបានកើនឡើងដល់ ១២,៨លាននាក់។ ប្រជាជនកម្ពុជាបានកើនឡើងជាលំដាប់ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ ប្រជាជនកម្ពុជាបានកើនដល់ ១៣,៤លាននាក់ ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មដោយអង្កេតចន្លោះជំរឿនកម្ពុជាឆ្នាំ២០១៣ មានចំនួនប្រមាណ ១៤,៧លាននាក់ និងចុងក្រោយនេះ លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់មានចំនួន ១៥,៦ លាននាក់។[២៥]

### ១.៣.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកណាស់នៅក្នុងការកំណត់ ប៉ុន្តែជាទូទៅភាពក្រីក្រសំដៅដល់ការដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមភាគច្រើនការកំណត់ពីភាពក្រីក្រតាមរយៈ ប្រាក់ចំណូលទាប ដែលគេមិនអាចចាយវាយបានគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ ជាតម្រូវការរូបកាយតាមរយៈចំណីអាហារ លំនៅដ្ឋាន ការងារធនធានទឹក អគ្គិសនី អនាម័យ សុខមាលភាពសង្គម មានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ ការសម្គាល់ពីភាពក្រីក្របានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលរូបណាមួយ ព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះបានឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង ២០% ចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ ៩០% ក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[២៦]

កត្តានៃភាពក្រីក្រនេះ ក៏ជាកត្តាធ្វើឱ្យកើតមានឡើងនូវបញ្ហាផ្សេងៗដែលបង្កភាពប៉ះពាល់សណ្ដាប់ធ្នាប់ និងរបៀបរៀបរយផងដែរ។ នេះក៏ដោយសារកត្តាជីវភាពក្រីក្រ ប្រជាពលរដ្ឋភាគច្រើនគ្មានទីលំនៅសម្រាប់រស់នៅឱ្យបានសមរម្យធ្វើឱ្យអ្នកខ្លះត្រូវដេក ឬសម្រាកតាមចិញ្ចើមផ្លូវ និងសួនច្បារជាដើម។ ម្យ៉ាងទៀតដោយតែការខ្វះខាតអាហារហូបចុកមិនបានគ្រប់គ្រាន់ ប្រជាពលរដ្ឋមួយចំនួនក៏ត្រូវដើរសុំទានដើម្បីបំពេញតម្រូវការក្រពះ។ បញ្ហាទាំង

[២៥] សៀវភៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយ, ទំព័រទី១៨

[២៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៧

អស់នេះហើយបានបង្កភាពប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ដែលជាហេតុធ្វើឱ្យអាជ្ញាធរក្រុង ត្រូវយកចិត្តទុកដាក់ស្វែងរកដំណោះស្រាយ និងរៀបចំធ្វើយ៉ាងណាឱ្យភាពល្អប្រសើរ។

### ១.៣.៣. កម្រិតជីវភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាពរស់នៅប្រចាំថ្ងៃ គឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាក្នុងការជំរុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាពនៃការរស់នៅរបស់ប្រជាជនក្នុងក្រុង ភាពស៊ីវិល័យ ភាពសម្បូរការងារ និងទទួលបានប្រាក់បៀវត្សខ្ពស់នៅក្រុងជាកត្តាមួយដែលបានទាក់ទាញឱ្យមនុស្សចង់មករស់នៅក្នុងក្រុង។ ដរាបណាភាពខុសគ្នារវាងក្រុង និងជនបទនៅតែមានគម្លាតខ្ពស់ ប្រជាពលរដ្ឋដែលរស់នៅជនបទ នៅតែចង់ចំណាកស្រុកមករស់នៅក្នុងក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានីតិកម្មភាពខ្ពស់ជាកត្តាជំរុញការចំណាកស្រុក ដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ក្រុងផងដែរ។ លើសពីនេះទៅទៀតក្រុងបានប្រមូលផ្តុំទៅដោយកត្តាសង្គម នយោបាយល្អប្រសើរ ខណៈពេលដែលសេវាសុខាភិបាល និងការអប់រំមានភាពសម្បូរបែបរឹតតែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[២៧] តួយ៉ាងនៅក្នុងក្រុង មានការបម្រើសេវាសាធារណៈសម្បូរបែប និងឆាប់រហ័សជាងនៅជនបទជាក់ស្តែងដូចជា សេវាសុខាភិបាលនៅតាមតំបន់ជនបទដាច់ស្រយាលមួយចំនួន មណ្ឌលសុខភាពពុំទាន់មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់នៅឡើយ អគារស្នាក់នៅរបស់អ្នកជំងឺ មណ្ឌលសុខភាពនៅឆ្ងាយពីលំនៅឋាន។ ចំពោះផ្នែកអប់រំនៅក្នុងក្រុងមានទាំងសាលារដ្ឋ និងសាលាឯកជន ទាំងភាសាខ្មែរ និងភាសាបរទេស រីឯនៅជនបទវិញមានតែសាលារដ្ឋ ហើយសាលាខ្លះក៏ពុំទាន់មានអគារសិក្សាត្រឹមត្រូវនៅឡើយនោះទេ។ ដោយសារបញ្ហាទាំងអស់នេះហើយទើបតម្រូវឱ្យប្រជាជនប្រមូលផ្តុំមករស់នៅក្នុងក្រុង និងដើម្បីងាយស្រួលក្នុងការទទួលសេវាសាធារណៈ ដែលតម្រូវឱ្យក្រុងត្រូវតែមានការរៀបចំសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ និងមានជាសុខភាព ដូច្នេះហើយកម្រិតជីវភាពនៃការរស់នៅ ក៏ជាកត្តាមួយដែលជំរុញឱ្យមានការរៀបចំក្រុងផងដែរ។

### ១.៣.៤. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋរស់នៅជនបទពាក់ព័ន្ធទៅនឹងវិស័យបរិស្ថាន គឺបញ្ហាកង្វះដីសម្រាប់ការបង្កបង្កើនផល ដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតាឪពុកម្តាយរបស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះគ្មាន

[២៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៨

ដីវជាតិទៀតនោះ។ ប្រសិនបើក្រឡេកមើលទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាខ្វះប្រព័ន្ធធារាសាស្ត្រ ស្រោចស្រព និងជីកសិកម្មសម្រាប់ប្រើប្រាស់បង្កបង្កើនផលទៅវិញ។[២៨] កត្តាទាំងអស់នេះហើយជាផលវិបាកយ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋដែលរស់នៅជនបទ ដោយពួកគាត់ត្រូវពឹងផ្អែកលើការប្រកបរបរធ្វើស្រែចម្ការ សម្រាប់ចិញ្ចឹមជីវិត។

**១.៣.៥. គមនាគមន៍**

គមនាគមន៍ គឺជាកត្តាសំខាន់មួយផងដែរ ដែលជំរុញឱ្យមានការរៀបចំក្រុង។ ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយរបស់ក្រុងក៏អាស្រ័យទៅលើកត្តាផ្លូវថ្នល់ផងដែរ។ ការរីកចម្រើនផ្នែកកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទៅនឹងការរីកចម្រើនខាងផ្នែកគមនាគមន៍ ទាំងផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក ដែលសុទ្ធសឹងតែជាសសៃឈាមនៃសេដ្ឋកិច្ច។

គមនាគមន៍ គឺជាលក្ខណៈវិនិច្ឆ័យសំខាន់មួយឱ្យយើងដឹងពីការអភិវឌ្ឍរបស់ក្រុងណាមួយ ឬប្រទេសណាមួយ។ កាលណាក្រុងមានការរីកចម្រើនផ្នែកគមនាគន៍ មានផ្លូវថ្នល់ខ្វាត់ខ្វែងដែលអាចសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើរផ្សេងៗទៀតបានយ៉ាងល្អប្រសើរ ដោយគ្មានការកកស្ទះ ឬជួបនូវបញ្ហាផ្សេងៗនោះ និងធ្វើឱ្យក្រុងនោះមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អប្រសើរ ព្រមទាំងជំរុញឱ្យសេដ្ឋកិច្ចរបស់ក្រុង និងប្រទេសនោះមានការរីកចម្រើនផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើក្រុង ឬប្រទេសមួយខ្វះខាតនូវគមនាគមន៍ និងបង្កឱ្យមានការកកស្ទះរាំងស្ទះដល់ការដឹកជញ្ជូន ឬការធ្វើដំណើរផ្សេងៗ ហើយនាំឱ្យបាត់បង់សោភ័ណភាពសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ព្រមទាំងជាឧបសគ្គដល់ការរីកចម្រើននៃសេដ្ឋកិច្ចផងដែរ។

[២៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៨

# ជំពូកទី២
# ការរៀបចំសោភ័ណភាព និង
# សណ្តាប់ធ្នាប់ក្រុងកំពង់ចាម

# ជំពូកទី២
# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម

ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ធ្វើឱ្យក្រុង ខេត្ត ឬប្រទេសមួយដែលចាំបាច់ត្រូវតែមានការរៀបចំឱ្យមានភាពល្អប្រសើរ។ ចំពោះក្រុងកំពង់ចាម បានកំពុងតែយកចិត្តទុកដាក់ជាខ្លាំងទៅលើការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុង ដោយក្រុងកំពង់ចាមក៏ជាគោលដៅទេសចរណ៍មួយសម្រាប់ភ្ញៀវទេសចរជាតិ និងភ្ញៀវទេសចរអន្តរជាតិផងដែរ។

## ២.១. បច្ចុប្បន្នភាពការរៀបចំក្រុងកំពង់ចាម

តាមរយៈការសង្កេតមើលអំពីស្ថានភាពជាក់ស្តែងចំពោះការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុងកំពង់ចាមរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ បានបង្ហាញឱ្យឃើញអំពីការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុងកំពង់ចាម ដែលត្រូវបានរដ្ឋបាលក្រុងកំពង់ចាម និងរដ្ឋបាលខេត្តកំពង់ចាមធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីរក្សាឱ្យបាននូវភាពស្រស់បំព្រង និងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយសុខមាលភាព អនាម័យដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងកំពង់ចាម ព្រមទាំងរក្សាឱ្យបាននូវសោភ័ណភាព និងសណ្តាប់ធ្នាប់ទាំងពេលថ្ងៃ និងពេលយប់ជូនប្រជាពលរដ្ឋផងដែរ។ កន្លងមកនៅក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្នុងក្រុងកំពង់ចាម នៅមានភាពខ្វះចន្លោះមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ ដោយហេតុថាកត្តាប្រជាពលរដ្ឋមួយចំនួនមិនទាន់មានការយល់ដឹង និងកង្វះថវិកាក្នុងការរៀបចំនៅមានកម្រិតដែលធ្វើឱ្យមានការខ្វះខាតក្នុងការរៀបចំរួមមាន សួនច្បារ ការបំពាក់ភ្លើងបំភ្លឺ ស្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ ការស្តារជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅមានចំនួនតិចតួចដែលមិនទាន់មានសោភ័ណភាពបានល្អប្រសើរនៅឡើយ។ បញ្ហាទាំងអស់នេះ គឺជាបញ្ហាចោទមួយដ៏សំខាន់ដែលតម្រូវអាជ្ញាធរក្រុង និងមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ត្រូវធ្វើការដោះស្រាយបញ្ហាទាំងអស់នេះឱ្យបានទាន់សភាពការ ដើម្បីធានារក្សានូវសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយនៅក្នុងក្រុងកំពង់ចាមឱ្យមានភាពល្អប្រសើរ។

ម្យ៉ាងវិញទៀត ដោយមានការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល រដ្ឋបាលក្រុងកំពង់ចាម និងមន្ត្រីជំនាញពាក់ព័ន្ធទាំងអស់បានធ្វើឱ្យក្រុងកំពង់ចាម ក្លាយជាក្រុងមួយមានភាពស្រស់ស្អាត និងភាពទាក់ទាញដល់ភ្ញៀវទេសចរជាតិ និងភ្ញៀវទេសចរអន្តរជាតិចូលមកលេងកម្សាន្ត។ ដោយសារតែមានសោភ័ណភាពស្រស់ស្អាតទាំងពេលយប់ និងពេលថ្ងៃ។

ចំណែកឯនៅពេលយប់វិញ នៅក្នុងក្រុងកំពង់ចាម មានភ្លើងបំភ្លឺនៅតាមដងវិថី និងអគារតូចធំព្រមទាំងមានផ្សាររាត្រីសម្រាប់ដើរកម្សាន្ត និងសួនមាត់ទន្លេដើម្បីស្រូបយកខ្យល់អាកាសដ៏បរិសុទ្ធនៅតាមដង

ទន្លេមេគង្គ។ ប៉ុន្តែទោះបីជាមានការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធយ៉ាងណាក៏ដោយ ក្រុងកំពង់ចាមនៅតែមិនអាចជៀសវាងនូវការបំពុលទាំង៥ ដែលបានកើតចេញពីកត្តាមនុស្ស និងធម្មជាតិបានឡើយ។ ដោយកត្តាបំពុលទាំងប្រាំនេះ បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន និងសុខមាលភាព ហេតុអាចបង្កផលប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋរស់នៅក្នុងក្រុងកំពង់ចាមផងដែរ។

### ២.១.១. ការរៀបចំសោភ័ណភាពក្រុងកំពង់ចាម

សោភ័ណភាព សំដៅលើភាពល្អប្រសើរក្រៃលែង ភាពល្អហ្មត់ហ្មង។[២៩] សោភ័ណភាព ក៏ជាកត្តាមួយដែលជំរុញឱ្យមានការរៀបចំក្រុង និងការអភិវឌ្ឍផ្សេងៗជាច្រើនទៀតឱ្យបានល្អប្រសើរ និងគ្រប់ទីកន្លែង គឺសុទ្ធតែទាមទារឱ្យមានភាពស្រស់ស្អាត ឬភាពល្អហ្មត់ហ្មងដើម្បីបង្កើនឱ្យមានភាពទាក់ទាញ និងតម្រូវការពីគ្រប់មជ្ឈដ្ឋានជុំវិញ។

#### ២.១.១.១. សោភ័ណភាពពេលថ្ងៃ

សោភ័ណភាពពេលថ្ងៃ គឺសំដៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ព្រមទាំងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញានឹងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ រាប់បញ្ចូលទាំងថ្មើរជើង ដែលប្រកបដោយសណ្ដាប់ធ្នាប់ និងរបៀបរៀបរយថែមទៀតផង។[៣០]

- **ការកសាងហេដ្ឋារចនាសម្ព័ន្ធលើដី**

ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅលើដី សំដៅទៅលើការកសាង និងការរៀបចំហេដ្ឋាចរនាសម្ព័ន្ធផ្សេងៗដែលមានដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ អគារ ស្លាកសញ្ញា និងភ្លើងសញ្ញាចរាចរណ៍ជាដើម។

ជាក់ស្ដែងនៅក្នុងក្រុងកំពង់ចាម រដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើនដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅរស់នៅក្នុងមូលដ្ឋាន ដែលហេដ្ឋារចនាសម្ព័ន្ធខ្លះត្រូវបានជួសជុលកែលម្អសារជាថ្មី ឬកសាងថ្មីឡើងវិញ។ ដោយបច្ចុប្បន្ននេះក្រុងកំពង់ចាមមានហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវក្រាលកៅស៊ូចំនួន ៤២ខ្សែ មានប្រវែងសរុបចំនួន ២២១១៦ម៉ែត្រ ផ្លូវក្រាលបេតុងចំនួន ២៥ខ្សែ មានប្រវែងសរុប ២៥៦២០ម៉ែត្រ និងផ្លូវក្រាលគ្រួសចំនួន ០៦ខ្សែ មានប្រវែងសរុបចំនួន ៧៣៦៤ម៉ែត្រ។ សួនច្បារសាធារណៈចំនួន ១៦កន្លែង មានផ្ទៃដីសរុបចំនួន ៥៦៨ហិកតា ដោយក្នុងនោះមានសួនកុមារ ០១កន្លែង កីឡាដ្ឋានចំនួន ០៣កន្លែង និងទីធ្លាសាធារណៈស្ថិតនៅតាមបណ្ដោយមាត់ទន្លេមានផ្ទៃដីសរុបចំនួន ០៥ហិកតា។ ផ្សារចំនួន ០៤កន្លែង ចំណតរថយន្តឈ្នួលមានចំនួន ០២កន្លែង និងចំណតរថយន្ត

[២៩] សម្ដេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ

[៣០] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

ក្រុងមានចំនួន ០៧កន្លែង មជ្ឈមណ្ឌលពាណិជ្ជកម្មមានចំនួន ០១កន្លែង ផ្សាររាត្រី ០១កន្លែង រមណីយដ្ឋានទេសចរណ៍មានចំនួន ០១កន្លែង។ ចំពោះអគារសាធារណៈមានដូចជា សាលាមតេយ្យរដ្ឋមានចំនួន ០៩កន្លែង សាលាបឋមរដ្ឋមានចំនួន ១១កន្លែង សាលាអនុវិទ្យាល័យរដ្ឋចំនួន ០២កន្លែង វិទ្យាល័យមានចំនួន ០៦កន្លែង គ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន ០៥កន្លែង គ្រឹះស្ថានសិក្សាឯកជនមានចំនួន ២១កន្លែង និងមន្ទីរពេទ្យរដ្ឋមានចំនួន ០៤កន្លែង។

❖ **ការកសាងហេដ្ឋារចនាសម្ព័ន្ធក្រោមដី**

ការកសាងហេដ្ឋារចនាសម្ព័ន្ធក្រោមដី គឺសំដៅទៅលើការកសាងប្រព័ន្ធលូ ពីព្រោះប្រព័ន្ធលូត្រូវតែមានការកសាង និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដើម្បីជៀសវាងនូវបញ្ហាកើតមានឡើង។ ជាក់ស្តែងកន្លងមកនៅក្នុងក្រុងកំពង់ចាម ក៏បានជួបបញ្ហាប្រព័ន្ធលូ នៅក្រោយពេលមានភ្លៀងខ្លាំងម្តងៗបានធ្វើឱ្យប្រព័ន្ធលូមានបញ្ហាកកស្ទះ និងប្រព័ន្ធមួយចំនួនទៀតរំដោះទឹកភ្លៀងមិនទាន់ ដោយឃើញកត្តាទាំងអស់នេះហើយទើបរដ្ឋបាលក្រុង ក៏ដូចជាមន្ត្រីជំនាញ ដែលពាក់ព័ន្ធបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការរៀបចំប្រព័ន្ធលូឱ្យមានបានល្អប្រសើរនៅក្នុងក្រុងកំពង់ចាម។

ដោយបច្ចុប្បន្ននៅក្នុងគម្រោងអភិវឌ្ឍន៍ក្រុងជំហានទី៤ អនុគម្រោងសាងសង់ប្រព័ន្ធលូ និងស្ថានីយប្រព្រឹត្តកម្មទឹកកង្វក់ក្រុងកំពង់ចាមក្រោមកម្ចីឥណទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ ហើយគម្រោងនេះស្ថិតនៅក្រោមអង្គភាពគ្រប់គ្រងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រួតពិនិត្យបច្ចេកទេសដោយក្រុមហ៊ុន RAMBOLL DANMARK A/S សហការជាមួយក្រុមហ៊ុន Oriental Consultant Global Co.Ltd ក្រុមហ៊ុន SCE និងក្រុមហ៊ុន Tancons (Cambodia) Co.Ltd និងម៉ៅការសាងសង់ដោយក្រុមហ៊ុន Beijing Urban Construction Group Co.Ltd (BUCG)។ ដោយការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួមមានការតភ្ជាប់បណ្តាញទឹកកង្វក់តាមផ្ទះ និងអគារការិយាល័យផ្សេងៗចំនួន ៣៩៦៥កន្លែង ប្រព័ន្ធបណ្តាញទុយោមេ និងរងប្រវែង ៥១គីឡូម៉ែត្រ ស្ថានីយបូមមេ និងរងចំនួន ៣កន្លែង ស្ថានីយប្រព្រឹត្តកម្មទឹកកង្វក់ចំនួន ០១កន្លែង ដែលមានសមត្ថភាព ៥០០០ម៉ែត្រគូប/មួយថ្ងៃ។ ប្រព័ន្ធលូរំដោះទឹកភ្លៀងរួមមាន លូបង្ហូររៀបថ្មរាងអក្សរ V ប្រវែង ២៩២៩ម៉ែត្រ លូបេតុងប្រអប់ប្រវែង ៩០ម៉ែត្រ លូបេតុងបូលប្រវែង ២៨៤ម៉ែត្រ លូបេតុងរាងអក្សរ U ប្រវែង ៨៩,៩ម៉ែត្រ កន្លែងបង្ហូរចេញចំនួន ០១កន្លែង និងស្ថានីយបូមចំនួន ០១កន្លែង។[៣១]

ដោយមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងក្រុងកំពង់ចាម គឺសំដៅការលើកកម្ពស់សុខមាលភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងក្រុងកំពង់ចាម និងការពារបរិស្ថានប្រកបដោយនិរន្តភាព តាមរយៈគម្រោង

[៣១] ដកស្រង់ពីគេហទំព័រ https://www.mpwt.gov.kh/kh/press/32191 ចូលមើលថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣

សាងសង់ប្រព័ន្ធលូខ្វាត់ខ្វែង ក្នុងភូមិសាស្ត្រសង្កាត់កំពង់ចាម សង្កាត់វាលវង់ និងផ្នែកខ្លះនៃសង្កាត់បឹងកុក សង្កាត់សំបួរមាស និងកសាងស្ថានីយប្រព្រឹត្តទឹកកង្វក់មុននឹងទឹកបង្ហូរចូលទៅក្នុងបឹងធម្មជាតិ ហើយគម្រោងនេះនឹងបញ្ចៀសការជន់លិចដោយសារទឹកភ្លៀង និងមានការបែងចែកច្បាស់លាស់រវាងប្រព័ន្ធលូរំដោះទឹកភ្លៀង និងប្រព័ន្ធលូរំដោះទឹកកង្វក់។

### ២.១.១.២. សោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ គឺសំដៅដល់ការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងវិថីនានានៅក្នុងក្រុងជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមទីសាធារណៈនានានៅក្នុងក្រុង។[៣២] ម្យ៉ាងទៀតគឺជាការលម្អដែលធ្វើឱ្យក្រុងកាន់តែមានសោភ័ណភាពជាមួយ និងការបំភ្លឺបែបនេះ។ ចំណែកនៅក្នុងការធ្វើដំណើរទៀតសោត ជាពិសេសក្រុងកំពង់ចាមបានផ្តល់ភាពងាយស្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋរស់នៅក្នុងក្រុង និងប្រជាពលរដ្ឋដែលបានធ្វើដំណើរឆ្លងកាត់ផងដែរ។

ការអភិវឌ្ឍក្រុងឱ្យមានសោភ័ណភាពស្រស់បំព្រងនាពេលរាត្រី ត្រូវផ្តោតសំខាន់ទៅលើការបំពាក់ភ្លើងបំភ្លឺទាំងការបំភ្លឺតាមដងវិថី និងការបំភ្លឺទៅតាមសំណង់អគារតូចធំទាំងរដ្ឋ និងឯកជន ព្រមទាំងការបំពាក់ភ្លើងបំភ្លឺនៅតាមសួនច្បារសាធារណៈ តាមបង្កាន់ដៃស្ពាន និងតាមទីសាធារណៈ ដែលធ្វើឱ្យក្រុងកាន់តែមានសោភ័ណភាព។ ជាក់ស្តែងក្រុងកំពង់ចាម បានបំពាក់ភ្លើងបំភ្លឺតាមដងផ្លូវ អគារតូចធំទាំងរដ្ឋ ទាំងអគារឯកជន និងបានរៀបចំប្រព័ន្ធភ្លើងនៅតាមសួនច្បារមាត់ទន្លេ និងសួនកុមារនៅក្នុងក្រុងផងដែរ។ ចំពោះការរៀបចំបំពាក់ភ្លើងបំភ្លឺពេលយប់នៅតាមដងផ្លូវ អគារតូចធំ សួនច្បារសាធារណៈក្នុងក្រុងកំពង់ចាម បានលើកកម្ពស់នូវសោភ័ណភាពក្នុងក្រុងថែមមួយកម្រិតទៀត ដោយសារតែសួនច្បារសាធារណៈ គឺជាកន្លែងសម្រាប់ទទួល ប្រជាពលរដ្ឋរស់នៅក្នុងក្រុង ក៏ដូចជាភ្ញៀវទេសចរជាតិ និងភ្ញៀវទេសចរអន្តរជាតិចូលមកទស្សនានៅក្នុងក្រុងកំពង់ចាម ចូលមកថតរូបលេងកម្សាន្ត និងសម្រាប់ប្រជាពលរដ្ឋដែលមកលំហែបន្ធូរអារម្មណ៍តានតឹង និងធ្វើការលំហាត់ប្រាណនៅពេលចុងសប្តាហ៍។

### ២.១.២. ការរៀបចំសណ្តាប់ធ្នាប់ក្រុងកំពង់ចាម

ជាគោលការណ៍ក្រុងមួយដែលមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អប្រសើរត្រូវឈរលើគោលការណ៍៣សំខាន់ៗគឺ៖ សន្តិសុខ ភាពស្មៀមស្ងាត់ និងគ្មានការបំពុលទាំង៥។[៣៣]

### ២.១.២.១. សន្តិសុខ

ដើម្បីឱ្យទីក្រុងមួយមានសណ្តាប់ធ្នាប់ គឺត្រូវធានាឱ្យបាននូវ សន្តិសុខ សុវត្ថិភាព សេចក្តីសុខសាន្ត និងគ្មានភាពចលាចលផ្សេងៗបានកើតឡើង។ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលលើការងារសន្តិសុខ

[៣២] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

[៣៣] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

សណ្តាប់ធ្នាប់សាធារណៈ ដោយស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ជូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងឱ្យរស់នៅប្រកបដោយសុវត្ថិភាព និងសន្តិភាព។ លើសពីនេះទៅទៀតរាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ក្នុងគោលបំណងធានាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅតាមភូមិ ឃុំនីមួយៗ។ ជាការពិតណាស់នៅក្នុងសន្តិសុខត្រូវបានកំណត់គោលការណ៍សំខាន់ៗបីរួមមានដូចជា សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។[៣៤]

❖ **សុវត្ថិភាពបុគ្គល**

សុវត្ថិភាពបុគ្គល គឺសំដៅដល់សុវត្ថិភាពរបស់បុគ្គលគ្រប់រូប និងសេរីភាពរបស់បុគ្គលម្នាក់ៗដែលគ្មានការបំពានពីសំណាក់បុគ្គលណាមួយឡើយ ដែលជាហេតុនាំឱ្យមានការបង្កបញ្ហាពោល គឺមានសុវត្ថិភាព និងមានការការពារជូនដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះផងដែរ ការជំរុញឱ្យមានការពង្រឹងគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព។ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព បានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គលផងដែរ ហើយគោលនយោបាយនេះមានលក្ខណៈសម្បត្តិ ៩មានដូចខាងក្រោម៖

១. គ្មានសកម្មភាពលួច ឆក់ប្លន់ គ្រប់ប្រភេទ។
២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ។
៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ។
៤. គ្មានក្មេងទំនើង។
៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសគ្រប់ប្រភេទ។
៦. គ្មានគ្រោះថ្នាក់ចរាចរណ៍។
៧. គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។
៨. មានវិធានការណ៍ទប់ស្កាត់គ្រប់គ្រង និងការឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
៩. គ្មានការត្រួតពិនិត្យខុសច្បាប់។[៣៥]

ជាមួយគ្នានេះផងដែរ យោងតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃក៏បានបន្ថែមផងដែរថា ដោយយោងតាមលទ្ធផលនៃការប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ប្រចាំឆ្នាំ២០១៨ របស់

[៣៤] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

[៣៥] ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព, លេខ០២០ ជ.ក, ១៦ សីហា ២០១០

ក្រសួងមហាផ្ទៃ បានបង្ហាញឱ្យឃើញថាក្នុងចំណោម ឃុំ/សង្កាត់ទាំង១២៧ របស់រដ្ឋបាលខេត្តកណ្ដាល ទទួលបានចំណាត់ថ្នាក់ប្រភេទ១ បានចំនួន៥០/៥៧ឃុំ ប្រភេទ២ ទទួលបាន ៦៩/៦១ ឃុំ សង្កាត់ ចំណាត់ថ្នាក់ប្រភេទ ៣ ទទួលបាន ៨/៩ឃុំ និងគ្មានចំណាត់ថ្នាក់មានចំនួន ០ឃុំ។

ទោះបីជាទទួលបានលទ្ធផលគួរជាទីល្អប្រសើរក៏ពិតមែន ប៉ុន្តែនៅក្នុងការប្រព្រឹត្តទៅនៃចលនាអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពនៅមានបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធដល់ការងារពង្រឹងតួនាទីការដឹកនាំ ការផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ការកសាងកម្លាំងប្រជាការពារ ការរៀបចំវេទិការសាធារណៈ ពិសេសការបំផុសចលនាប្រឡងប្រណាំងនៅមិនទាន់ស៊ីជម្រៅ នៅមានលក្ខណៈស្មុគស្មាញ និងបន្ទុកការងារកាន់តែច្រើន។ ដូចនេះគណៈបញ្ជាការឯកភាពក្រុង ស្រុក កងកម្លាំងមានសមត្ថកិច្ច ព្រមទាំងមាននូវអាជ្ញាធរពាក់ព័ន្ធត្រូវបន្តប្រកាន់ខ្ជាប់នូវទស្សនៈ ភូមិ ឃុំ មានសុវត្ថិភាពជាភារកិច្ចសំខាន់សម្រាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ បង្កើនការប្រមូលផ្តុំដឹកនាំក្នុងមូលដ្ឋានឱ្យចូលរួមសកម្ម ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការកសាងផែនការប្រើប្រាស់កម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ព្រមទាំងមានកម្មវិធីប្រជុំបូកសរុប ដកពិសោធន៍តាមដំណាក់កាលនីមួយៗ គឺសំដៅកែលម្អបង្កើនប្រសិទ្ធភាពថែមទៀតសម្រាប់រដ្ឋបាលក្រុង ស្រុករបស់ខ្លួន។ បង្កើតការរៀបចំនូវវេទិកាសាធារណៈឱ្យកាន់តែសកម្មបន្ថែមទៀត ដោយយកចិត្តទុកដាក់ខ្ពស់អំពីគុណភាពនៃការទទួលបានព័ត៌មាន អំពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធ និងបញ្ហាសន្តិសុខ ព្រមទាំងបានខិតខំដោះស្រាយនូវរាល់សំណូមពរប្រជាពលរដ្ឋបានលើកឡើងឱ្យរួសរាន់ ប្រកបដោយស្មារតីទទួលខុសត្រូវ គឺសំដៅដល់ការធ្វើឱ្យវេទិកាសាធារណៈមួយឱ្យទទួលបាននូវគុណប្រយោជន៍ពិតៗ ហើយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងខេត្តត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ និងដើម្បីឱ្យការអនុវត្តនូវគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ទទួលបានលទ្ធផលល្អ ធានាការពារសន្តិសុខ និងសណ្តាប់ធ្នាប់ ដល់ប្រជាពលរដ្ឋដែលរស់នៅគ្រប់ទីកន្លែង ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។[៣៦]

- ❖ **សុវត្ថិភាពសម្ភារៈ**

សុវត្ថិភាពសម្ភារៈនៅពេលនេះ គឺចង់បានន័យថាមិនត្រឹមតែមិនមានការឆក់ប្លន់នោះទេ ពោល គឺមានសុវត្ថិភាពដល់សម្ភារៈដែលបម្រើដល់ការរស់នៅរបស់ប្រជាជនរួមមានដូចជា មិនមាននូវការគាស់ផ្ទះ ផ្លោះរបងឬការគាស់ទូរធនាគារ ក្មេងពាល ល្បែងស៊ីសង ឬសកម្មភាពផ្សេងទៀតដែលបង្កឱ្យមានភាពអសន្តិសុខដែលធ្វើឱ្យមានភាពភ័យខ្លាច ដល់ការរស់នៅរបស់ប្រជាជនភូមិ ឃុំ សង្កាត់ផងដែរ។ ជាមួយគ្នានេះ ក៏ត្រូវមានសន្តិសុខ

[៣៦] ដកស្រង់គេហទំព័រ https://www.interior.gov.kh/report/detail/2325 ចូលមើលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣

សុវត្ថិភាព ដោយមានការឃាមពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធ បន្ថែមទៀតសម្រាប់ ភាពកក់ក្តៅរបស់ប្រជាពលរដ្ឋជាមួយនឹងការការពារដោយការយកចិត្តទុកដាក់ខ្ពស់ជាមួយ និងបញ្ហាសន្តិសុខ។ ការគិតគូរបែបនេះ មិនត្រឹមតែធ្វើឱ្យប្រជាជនមានទំនុកចិត្តនោះទេ ថែមទាំងធ្វើឱ្យជនជាតិបរទេសជាពិសេសជាមួយផ្នែកទេសចរណ៍ដែលធ្វើឱ្យមានទំនុកចិត្តជាមួយដំណើរកម្សាន្ត។ លើសពីនេះទៅទៀត កាលណាពួកគាត់មាននូវសុវត្ថិភាពពេលចូលមកដល់ប្រទេសកម្ពុជា នោះធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងសម្រាប់ការងារ រកស៊ីបណ្តាក់ទុន ព្រោះជាប្រទេសដែលមានសុវត្ថិភាព ដូច្នេះការរកស៊ីក៏មានសុវត្ថិភាពផងដែរ។ ស្ថិតក្នុងបរិបទបែបនេះការវិនិយោគកាន់តែកើនឡើង ជាហេតុបណ្តាលឱ្យសេដ្ឋកិច្ចជាតិកាន់តែមានការអភិវឌ្ឍ និងជួយបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋផងដែរតាមរយៈទេសចរណ៍ ក៏ដូចជាការវិនិយោគ។

❖ **សុវត្ថិភាពចំណីអាហារ**

បច្ចុប្បន្ននេះរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីពាក់ព័ន្ធផ្សេងៗបានខិតខំព្យាយាមទប់ស្កាត់ និងផាកពិន័យរាល់ការនាំចូលនូវរបស់របរ បន្លែ និងចំណីអាហារដែលមិនមានគុណភាពនៅតាមព្រំដែន ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយតម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋមានច្រើន។ ដើម្បីបំពេញតម្រូវការឱ្យបានគ្រប់នូវការប្រើប្រាស់នេះត្រូវទាមទារឱ្យមានចូលរួមពីប្រជាពលរដ្ឋក្នុងការដាំដំណាំ បន្លែ ផ្លែឈើ គ្មានសារជាតិគីមីដោយខ្លួនឯងសម្រាប់ទុកប្រើប្រាស់ និងដាក់លក់នៅលើទីផ្សារ ដើម្បីផ្តល់សុវត្ថិភាពដល់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិ។ ចំពោះអ្នកផលិតម្ហូបអាហារ បន្លែ ត្រូវមានគុណធម៌ សច្ចធម៌ មានបច្ចេកទេសខ្ពស់ ដើម្បីជួយបម្រើដល់សុខភាពរបស់អ្នកប្រើប្រាស់ កុំដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឱ្យប៉ះពាល់ ដល់សុខភាពរបស់អ្នកដទៃ តាមរយៈការលក់ទៅឱ្យអតិថិជន។ ចំពោះអ្នកប្រើប្រាស់ក៏គួរគប្បីស្វែងយល់ឱ្យបានច្រើននូវរាល់របស់ដែលមិនមានគុណភាពផលិតផលណាដែលគួរប្រើប្រាស់ និងមិនគួរប្រើប្រាស់ដូចគ្នាផងដែរ។

សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដើម្បីទទួលបានសុវត្ថិភាពចំណីអាហារ បើអាចពិនិត្យលើគុណភាពចំណីអាហារ គួរគប្បីមុននឹងទិញផលិតផលយកទៅប្រើប្រាស់ យ៉ាងហោចណាស់ក៏បានពិនិត្យមើលទៅលើកាលបរិច្ឆេទផុតកំណត់ឱ្យបានមួយចំណុចជាមុនសិន ដើម្បីធានាឱ្យដឹងថាផលិតផលនោះនៅអាចប្រើប្រាស់បាន ហើយបើកន្លែងកាលបរិច្ឆេទផុតកំណត់មានការកោសលុប មិនត្រូវទិញយកទៅប្រើប្រាស់នោះឡើយ។[៣៧]

ជារួមអាហារដែលមានសុវត្ថិភាព គឺយើងត្រូវពិនិត្យទៅលើបញ្ហាមួយចំនួនដែលជាកត្តាចាំបាច់ដូចជាកាលបរិច្ឆេទនៃការផុតកំណត់ អនាម័យ ការវេចខ្ចប់ ការទទួលស្គាល់ជាលក្ខណៈស្តង់ដារ។ ជាពិសេសជាងនេះ

---

[៣៧] ដកស្រង់ពីគេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣

ទៅទៀតស្ថាប័នដែលពាក់ព័ន្ធខាងគីមីចំណីអាហារ គឺត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងថែរក្សាសុខភាពរបស់ប្រជាជន និងអនុវត្តន៍យ៉ាងតឹងរឹងតាមរយៈការចុះត្រួតពិនិត្យទំនិញខុសច្បាប់ និងដាក់ទោសជនដែលនាំចូល ឬលក់ផលិតផលចំណីអាហារដែលខូចគុណភាព នាំឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់។ រួមជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋដែលលក់ចំណីអាហារក៏ត្រូវចូលរួមចំណែកដូចគ្នា ក្នុងការថែរក្សាអនាម័យចំណីអាហារដើម្បីសុខភាពអ្នកបរិភោគ។ យោងតាមសេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដែលត្រូវបានហាមឃាត់មានចំនួន ០៦ប្រភេទដូចខាងក្រោម៖

- ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ
- គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ
- ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់
- ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង កាហ្វេ ការ៉េម ទឹកស៊ីរ៉ូប៍គ្រប់ប្រភេទ
- ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ
- ចាហួយគ្រប់ប្រភេទ នំដូណាត់ នំផ្អែមខ្លាំង។[៣៨]

❖ **ចរាចរណ៍នៅក្នុងក្រុងកំពង់ចាម**

បញ្ហាចរាចរណ៍ ក៏ជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ជួយអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានភាពរីកចម្រើនជឿនលឿនទៅមុខផងដែរ។ កាលណាប្រទេសមានបញ្ហាកកស្ទះចរាចរណ៍នៅក្នុងក្រុង ជាការពិតណាស់វាមានគុណវិបត្តិផ្នែកសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋ។ ក៏ប៉ុន្តែបញ្ហាការកកស្ទះចរាចរណ៍ជាផ្នែកមួយដែលគួរឱ្យព្រួយបារម្ភពីព្រោះវាបានធ្វើឱ្យមានការបំពុលទៅដល់បរិស្ថាន និងប៉ះពាល់ទៅដល់សុខភាពមនុស្ស។ នៅក្នុងនោះផងដែរចំពោះក្រុងកំពង់ចាម ក៏មានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើការកកស្ទះចរាចរណ៍ ពីព្រោះការកកស្ទះចរាចរណ៍បានធ្វើឱ្យខ្យល់អាកាសមានសភាពអាប់អួរដោយសារតែម៉ូតូ រថយន្តបញ្ចេះម៉ាស៊ីនឥតឈប់ឈរមិនអាចរំលត់បានដែលវាអាចបណ្តាលឱ្យមាននូវគុណវិបត្តិសម្រាប់ប្រជាពលរដ្ឋជាច្រើនដូចជា ខាតបង់ពេលវេលា ប៉ះពាល់សុខភាព ព្រមទាំងបំពុលដល់បរិស្ថានតាមរយៈផ្សែងបំពង់ស៊ីម៉ាំងម៉ូតូ និងរថយន្តគ្រប់ប្រភេទ។ ជាក់ស្តែងការកកស្ទះចរាចរណ៍ គឺបណ្តាលមកពីកត្តា ៣យ៉ាងរួមមាន៖

- **កត្តាមនុស្ស** មនុស្សបានកើនឡើងច្រើន មនុស្សភាគច្រើនបានប្រើប្រាស់មធ្យោបាយដោយយានជំនិះផ្ទាល់ខ្លួនដែលបណ្តាលឱ្យមានការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍។ ហើយគ្រោះថ្នាក់ចរាចរណ៍របស់

[៣៨] សេចក្តីណែនាំស្តីពីចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន, លេខ១៨ អយក.សណន, ០២ ឧសភា ២០១៩

មនុស្សទៀតសោត គឺកើតចេញពីការមិនគោរពច្បាប់ចរាចរណ៍ មិនគោរពភ្លើងសញ្ញាចរាចរណ៍ ស្លាកសញ្ញា បើកបរមិនមានការអធ្យាស្រ័យ និងមិនយោគយល់ឱ្យគ្នាទៅវិញទៅមក។

- **កត្តាយានយន្ត** នៅក្នុងប្រទេសកម្ពុជាសម្បូរទៅដោយយានយន្តមួយទឹក២ ដែលនាំចូលមកពីបរទេស សម្រាប់លក់ជូនប្រជាពលរដ្ឋនៅក្នុងស្រុក ប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរ និងប្រើប្រាស់ប្រចាំថ្ងៃនេះ ក៏ជាហេតុដែលបណ្តាលឱ្យបំពុលដល់បរិស្ថានផងដែរ។
- **កត្តាផ្លូវថ្នល់** កត្តាផ្លូវថ្នល់មិនទាន់បានឆ្លើយតបទៅតាមតម្រូវការនៅឡើយទេ ពីព្រោះទីរួមខេត្ត និងក្រុង ពុំទាន់មានផ្លូវលក្ខណៈស្តង់ដារ នៅមានលក្ខណៈតូច ផ្លូវជួសជុលច្រើនដង និងមិនមានផ្លូវអាកាស។

ជាក់ស្តែងប្រទេសកម្ពុជានៅក្នុងឆ្នាំ២០២២ មានរថយន្តគ្រប់ប្រភេទសរុបចំនួន ៩២ម៉ឺនគ្រឿង និងម៉ូតូ សរុបចំនួន ៥,២លានគ្រឿងដែលបានចុះបញ្ជីប្រើប្រាស់ និងបានចរាចរណ៍នៅតាមដងផ្លូវ បើធៀបនឹងឆ្នាំ១៩៩៨ ប្រទេសកម្ពុជាមានរថយន្តដែលចរាចរតាមផ្លូវតែ ៦,៥ម៉ឺនគ្រឿង និងម៉ូតូ ២០ម៉ឺនគ្រឿងប៉ុណ្ណោះ។[៣៩] ក្រៅពីបញ្ហា កើនឡើងនៅយានយន្តគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក៏មានបញ្ហាចោទ ដែលនាំឱ្យមានបញ្ហាកកស្ទះ ចរាចរណ៍ ដោយសារផ្លូវមានលក្ខណៈទ្រុឌទ្រោម និងតូចចង្អៀត មានការប្រេះស្រាំ ខ្វះការថែទាំ រថយន្តដឹកទំនិញ លើសទម្ងន់ យកចំណីផ្លូវជាចំណត ប្រជាពលរដ្ឋមួយចំនួននៅខ្វះការយល់ដឹងពីការអនុវត្តច្បាប់ចរាចរណ៍ជាដើម។

### ២.១.២.២. ភាពស្ងៀមស្ងាត់

ភាពស្ងៀមស្ងាត់ សំដៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសំឡេង។[៤០] ស្ថិតក្នុងបរិបទបែប នេះការដែលមិនមានការបំពុលដោយសំឡេង ជាការរស់នៅដោយមានភាពស្ងៀមស្ងាត់ដោយមិនមានការរំខាន ដោយសំឡេងផ្សេងៗដែលអាចបង្កជាការរំខានដល់ការរស់នៅប្រចាំថ្ងៃ ដែលបានចេញមកពីប្រភពផ្សេងៗជាច្រើន ដូចជា មិនមានសំឡេងចេញពីការដ្ឋាន រោងចក្រសហគ្រាស សំឡេងតាមរយៈបំពងសំឡេង ឬចេញពីប្រភព ណាមួយ រួមទាំងការរំខានដោយសំឡេងគ្រប់ប្រភេទ គឺត្រូវបានហាមឃាត់ ឬមានវិធានការយ៉ាងតឹងរឹងចំពោះ បញ្ហាទាំងអស់នេះ។ ម្យ៉ាងទៀតការធ្វើបែបនេះ បានធ្វើឱ្យការរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះទទួលបាន នៅការរស់នៅដែលប្រកបទៅដោយភាពស្ងៀមស្ងាត់ព្រោះមិនមានការរំខានដល់អារម្មណ៍ រាល់ការសម្រាករបស់ ប្រជាពលរដ្ឋនៅក្នុងតំបន់នោះពីប្រភពផ្សេងៗ។ បន្ថែមពីនេះទៅទៀត ភាពស្ងៀមស្ងាត់ពិតជាមានសារៈសំខាន់ សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងតំបន់នោះ ពីព្រោះបើមានការរំខានដោយសំឡេង ការរស់នៅ ប្រចាំថ្ងៃប្រាកដជាមានការពិបាកនៅក្នុងការរស់នៅ ត្រូវបានយាយីដោយការរំខានជាខ្លាំងដល់សតិអារម្មណ៍ ដោយមិនទទួលបានអារម្មណ៍សម្រាកគ្រប់គ្រាន់។ ដូច្នេះស្ថាប័នដែលពាក់ព័ន្ធត្រូវមានវិធានការសម្រាប់ទប់ស្កាត់

[៣៩] ដកស្រង់ពីគេហទំព័រ https://sbm.news/articles/61d409ef19d3cbfafaf225ef ចូលមើលថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៣

[៤០] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

ក៏ដូចជាមានវិធានការសម្រាប់ការគ្រប់គ្រងការបំពុលដោយសំឡេងជូនដល់ប្រជាពលរដ្ឋ នៅក្នុងគោលបំណង អាចធានាបានថាប្រជាពលរដ្ឋរស់នៅបានដោយភាពស្ងៀមស្ងាត់ដោយគ្មានការបំពុល ឬរំខានដោយសំឡេង ចំពោះការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ។

### ២.១.២.៣. បរិស្ថានក្នុងក្រុងកំពង់ចាម

កាលពីមុនបញ្ហាបរិស្ថានមិនសូវកើតមានឡើងដែលនាំឱ្យមានការព្រួយបារម្ភនោះទេ ពីព្រោះដោយសារ ចំនួនប្រជាជន និងការអភិវឌ្ឍនៅមានកម្រិត។ ប៉ុន្តែដោយសារកំណើនប្រជាជនកើនឡើងនៅពេលបច្ចុប្បន្ន និងការរីកចម្រើននៃសេដ្ឋកិច្ចយ៉ាងឆាប់រហ័សកំពុងបង្កឱ្យមានការបំពុលបរិស្ថានកើតមានឡើង។ សកម្មភាពនៃ ការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កើតជាផលវិបាកផ្នែកបរិស្ថានរួមមាន ការបំពុលខ្យល់ ការបំពុលទឹក ការបំពុល សំឡេង និងការបំពុលសំណល់រឹងជាដើម។

បរិស្ថាន គឺជាកត្តាមួយក្នុងការជំរុញឱ្យមានការរៀបចំក្រុងឱ្យបានល្អប្រសើរផងដែរ។ បញ្ហាអំពីបរិស្ថាន គឺប្រទេសទូទាំងសកលលោកទៅហើយដែលបានគិតគូរអំពីបញ្ហាបរិស្ថាន។ ដូច្នេះក្រុងកំពង់ចាម គឺជាក្រុងមួយ ក្នុងចំណោមក្រុងស្រុកទាំង១០ នៅក្នុងខេត្តកំពង់ចាម ថ្នាក់ដឹកនាំក្រុង និងមន្ត្រីជំនាញពាក់ព័ន្ធបានគិតគូរយ៉ាង ខ្លាំងទៅលើបញ្ហាបរិស្ថាននេះ ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងក្រុងទទួលបាននូវផាសុខភាពល្អ។

ប៉ុន្តែសំរាមនៅតែជាបញ្ហាចោទចំពោះបរិស្ថាននៅឡើយ ដោយសារប្រទេសមួយចំនួនកំពុងតែអភិវឌ្ឍន៍ ហើយការប្រមូលសំរាមនៅមានភាពខ្វះខាត បទពិសោធន៍ មធ្យោបាយ និងធនធានក្នុងការគ្រប់គ្រងប្រមូល សំរាម សំណល់រឹង ហើយការចូលរួមប្រើប្រាស់សេវាប្រមូលសំរាម និងបង់ថ្លៃសេវារបស់ប្រជាពលរដ្ឋប្រើប្រាស់ នៅមានកម្រិតនៅឡើយ និងកត្តាប្រជាពលរដ្ឋមិនចូលរួមសហការ ។ ចំណែងក្រុង ស្រុកមួយចំនួនមិនទាន់មាន ដីសម្រាប់រៀបចំជាទីលានចាក់សំរាមខណៈខេត្ត ឬក្រុងដែលមានកន្លែងចាក់សំរាមភាគច្រើនជាទីលានចំហ ចំពោះការកែច្នៃសំរាមវិញនៅមានកម្រិតទាបនៅឡើយ។

ដោយរដ្ឋបាលក្រុងកំពង់ចាម ក៏កំពុងបានសហការជាមួយមន្ទីរបរិស្ថានខេត្ត និងអង្គការអប់រំបរិស្ថាន និងកែច្នៃសំរាម (COMPOSTED) ដើម្បីចូលរួមកាត់បន្ថយសំរាមប្លាស្ទិកនៅតាមច្រាំងមាត់ទន្លេមេគង្គ និងនៅ ក្នុងប្រភពទឹក។ អង្គការ COMPOSTED បាននឹងកំពុងអនុវត្តន៍គម្រោងសម្អាតសំរាមប្លាស្ទិកក្នុងក្រុងកំពង់ចាម ដើម្បីលុបបំបាត់ចោលសំរាមចូលទៅក្នុងប្រភពទឹក ពោល គឺកាត់បន្ថយការបំពុលនៃសំរាមទៅលើជីវចម្រុះក្នុង ទឹកទន្លេ និងលើកកម្ពស់សោភ័ណភាពរបស់ក្រុងកំពង់ចាម។ ហើយសំរាមដែលប្រមូលបាន គឺត្រូវបានចែកទៅ តាមប្រភេទនីមួយៗ សម្រាប់កែច្នៃបន្ត និងមិនបានយកទៅចោលនៅទីលានចាក់សំរាមទាំង ១០០% នោះទេ។[៤១]

[៤១] ដកស្រង់ពីគេហទំព័រ https://www.kampucheathmey.com/local-news/307147 ចូលមើលថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣

ជាក់ស្តែងដោយក្រុងកំពង់ចាមស្ថិតនៅតាមបណ្តោយនៃទន្លេមេគង្គឆ្លងកាត់ និងបឹងស្នាយគ្របដណ្តប់នៅក្នុងសង្កាត់ពីរ សង្កាត់វាលវង់ និងសង្កាត់សំបួរមាសបានធ្វើឱ្យសក្តានុពលនៃក្រុងកំពង់ចាមមានភាពប្រសើរ និងមានអត្ថប្រយោជន៍អេកូឡូស៊ីដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ និងជាជម្រកយ៉ាងសំខាន់ដល់មច្ឆាជាតិ។ ប្រជាកសិករបានប្រកបមុខរបរដាំដំណាំរួមផ្សំនឹងបានទាញយកផលប្រយោជន៍ពីផ្នែកនេះយ៉ាងច្រើន និងស្ថិតនៅក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ។ ក្រុងកំពង់ចាម មានសោភ័ណភាពបៃតងស្រស់បំព្រងតាមសួនច្បារនៅតាមដងផ្លូវក្នុងក្រុង និងតាមជួរមាត់ទន្លេ ថ្នាក់ដឹកនាំខេត្តបានដាំកូនឈើរួមមាន ដើមលឿងរាជ ត្របែកព្រៃ អង្កាញ់ អមជុំវិញផ្លូវសួនច្បារមាត់ទន្លេ និងសួនកុមារ។ ហើយសួនទាំងអស់នោះ ជាកន្លែងហាត់ប្រាណដើម្បីសុខភាព និងជាកន្លែងកម្សាន្តរបស់ប្រជាពលរដ្ឋក្នុងក្រុង និងជាកន្លែងសម្រាប់ភ្ញៀវទេសចរចូលមកកម្សាន្ត ឬស្នាក់នៅក្នុងក្រុងកំពង់ចាមផងដែរ។ ទោះបីជាសក្តានុពលនៃក្រុងកំពង់ចាម មានសម្រស់ស្រស់បំព្រងយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋបានទទួលរងនូវការបំពុលបរិស្ថានដូចជា ការប្រើជីគីមី និងថ្នាំសម្លាប់សត្វល្អិត ពិសេសគឺបញ្ហាផ្សែងចេញពីសិប្បកម្មជួសជុល រថយន្ត ម៉ូតូ កំពុងប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋរស់នៅក្នុងក្រុងដោយប្រយោល។[៤២]

- **ការបំពុលទឹក**

ការបំពុលទឹកអាចត្រូវបានគេឱ្យនិយមន័យច្រើនយ៉ាងផ្សេងៗពីគ្នា។ ជាទូទៅការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានា បានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រតិកម្ម(ដកយកសារធាតុបំពុលចេញ)។ ហើយការបំពុលទឹកភាគច្រើនបណ្តាលមកពីសំណល់ដែលចេញពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។[៤៣] ទឹកពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ម្យ៉ាងទៀតការបំពុលទឹក គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម ហើយការបំពុលអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថានទៅតាមកម្រិតនៃការបំពុលទាំងនោះ។ ការបំពុលទឹកអាចកើតឡើងតាមរយៈមូលហេតុជាច្រើនដូចជា៖

[៤២] សៀវភៅ ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០២០-២០២៤) ក្រុងកំពង់ចាម

[៤៣] ដកស្រង់ពីគេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/ ចូលមើលថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣

- **ការបំពុលដោយឧស្សាហកម្ម**

ដោយសារតែឧស្សាហកម្ម ជាកន្លែងដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមី ការបំពុលដោយសំណល់អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់កុមារ និងធ្វើឱ្យការលូតលាស់យឺតជាងធម្មតា។ ហើយឧស្សាហកម្មដែលបំពុលច្រើនជាងគេ គឺឧស្សាហកម្មផលិតក្រដាស និងផលិតចំណីអាហារ។

- **ការបំពុលដោយកសិកម្ម**

ដើម្បីធ្វើស្រែចំការ ដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវ ការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជាដង្កូវ និងសត្វល្អិតជាដើម។ ការប្រើជី និងថ្នាំសម្លាប់សត្វល្អិត ជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ កសិដ្ឋានចិញ្ចឹមសត្វជ្រូក បង្កើតឱ្យមានលាមក និងទឹកនោម ដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ ហើយជ្រាបចូលក្នុងដី បំពុលទឹកផងដែរ។

- **ការបំពុលដោយវិទ្យុសកម្ម**

រោងចក្រនុយក្លេអ៊ែរ ដែលមានផ្ទុកសារធាតុអ៊ុយរ៉ាញ៉ូម ដើម្បីផលិតគ្រឿងអគ្គិសនី ដែលពួកយោធាប្រើប្រាស់នៅក្នុងនាវាមុជទឹក និងផលិតគ្រាប់បែក ដោយបន្សល់សំណល់ និងបញ្ចេញកាំរស្មីថាមពល ជាហេតុនាំឱ្យបង្កគ្រោះថ្នាក់ដល់សុខភាពបណ្ដាលឱ្យស្លាប់ មានជំងឺមហារីក ធ្វើឱ្យគ្មានកូន ឬធ្វើឱ្យទារកមានកាយសម្បទាមិនគ្រប់គ្រាន់ជាដើម។

- **ការបំពុលដោយសំណល់ផ្សេងៗ**

ការបោះចោលសំណល់ដូចជា៖ ថង់ប្លាស្ទិក កាតុង ក្រដាស កែវ សំណល់សរីរាង្គ សំបកដប សំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះមិនងាយរលាយទៅក្នុងធម្មជាតិ ទោះជារលាយក៏មានរយៈពេលយូរដែលធ្វើឱ្យបរិស្ថានមិនស្រស់ស្រាយ។ មិនតែប៉ុណ្ណោះការបោះចោលសំរាមពាសវាលពាសកាលនាំឱ្យស្ទះលូ និងត្រីងាប់ផងដែរ។[៤៤]

- **វិធានការនៃការការពារការបំពុលទឹក**
  - ប្រើប្រាស់ទឹកក្នុងការសន្សំសំចៃខ្ពស់
  - មិនត្រូវបោះចោលកាកសំណល់ ទាំងឡាយណាដែលបណ្ដាលឱ្យមានការកង្វក់ទឹក
  - មិនត្រូវប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
  - អប់រំប្រជាជនឱ្យបានយល់ច្បាស់ពីបញ្ហាបរិស្ថាន តម្លៃនៃការខូចខាត បញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធី សិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ

[៤៤] ដកស្រង់ពីគេហទំព័រ https://thmeythmey.com/m/?page=detail&id=58963 ចូលមើលថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣

- ក្រសួងពាក់ព័ន្ធត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថាន ត្រូវចេះគ្រប់គ្រង និងតាមដានជាតិពុលទាំងឡាយ ដែលបណ្តាលឱ្យកង្វក់ទឹក ហើយត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញនៅក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលក្នុងទឹកជាដើម
- ណែនាំអប់រំដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីយដ្ឋាន ក៏ដូចជាភោជនីយដ្ឋានឱ្យធ្វើអាងសម្អាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលក្នុងទឹក
- បង្កើតក្រុមចុះត្រួតពិនិត្យនឹងធ្វើការដាក់ពិន័យចំពោះអ្នកទាំងឡាយណាដែលធ្វើឱ្យមានកង្វក់ទឹក។[៤៥]

គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៤៦] ទន្ទឹមជាមួយគ្នានេះ ត្រូវបានហាមឃាត់ជាដាច់ខាតរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តន៍តាមកម្រិតស្តង់ដារ នៃការបញ្ចេញសំណល់រាវ។[៤៧]

❖ **មូលហេតុដែលឱ្យមានការបំពុលខ្យល់**

ការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និងធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និងការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កឱ្យមានផលប៉ះពាល់ គួរឱ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពរបស់មនុស្ស។[៤៨]

កត្តាចម្បងបង្កើតការបំពុលខ្យល់ បានកើតចេញពីឧស្សហកម្ម ការដឹកជញ្ជូន ការដុតបញ្ចេះប្រេងឥន្ធនៈ និងកសិកម្មផងដែរ។ ការបំពុលខ្យល់ ស្ថិតក្នុងចំណោមបញ្ហាប្រឈមផ្នែកសុខភាពធំបំផុតសម្រាប់ប្រជាជនពិភពលោក។ នេះបើយោងតាមការបញ្ជាក់របស់អង្គការសុខភាពពិភពលោក បើសិនជាគ្មានដំណោះស្រាយទេ ការស្លាប់របស់ប្រជាជននឹងបន្តកើនឡើងខ្លាំងនៅពេលអនាគត។

បើតាមទិន្នន័យអង្គការសុខភាពពិភពលោកប្រជាជនពិភពលោក ៩០(%)ភាគរយ ដែលស្រូបយកខ្យល់កខ្វក់រៀងរាល់ថ្ងៃ ហើយក្នុងមួយឆ្នាំមនុស្សប្រហែលប្រាំពីរ (៧)លាននាក់បានស្លាប់ ដោយសារតែការបំពុលខ្យល់ក្នុងនោះមានកើតជំងឺមហារីក ជំងឺផ្លូវដង្ហើម ជំងឺបេះដូង និងជំងឺសួតជាដើម។ អង្គការអន្តរជាតិដដែលនេះបានបន្ថែមទៀតថា កម្រិតបំពុលខ្យល់ខ្លាំងជាងគេបានកើតឡើងនៅតំបន់ភាគខាងកើតមេឌីទែរ៉ាណេ និងអាស៊ីអាគ្នេយ៍ដោយកម្រិតបំពុលនោះកើនឡើងប្រាំដងលើកម្រិតស្តង់ដាកំណត់របស់ខ្លួនឯណោះ។ ចំណែក

---

[៤៥] ដកស្រង់ពីគេហទំព័រ https://www.khsearch.com/qua/10411 ចូលមើលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

[៤៦] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ០៦ មេសា ១៩៩៩, មាត្រា១៨

[៤៧] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ២៧ អនក្រ.បក, ០៦ មេសា ១៩៩៩, មាត្រា៦

[៤៨] ដកស្រង់ពីគេហទំព័រ https://opendevelopmentcambodia.net/km/topics/air-pollution ចូលមើលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣

អ្នកស្លាប់កើនរហូតដល់ ៩០(%)ភាគរយ គឺស្ថិតនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមដែលរងការបំពុលដោយសារ កំណើនឧស្សាហកម្ម ការដឹកជញ្ជូន កសិកម្ម និងការដុតប្រេងឥន្ធនៈនៅតាមលំនៅឋាននានាផងដែរ។ បច្ចុប្បន្នការបំពុលខ្យល់នៅក្នុងក្រុងកំពង់ចាមកំពុងរងនូវការបំពុល ហើយនៅក្នុងការបំពុលនោះទៀតសោត គឺកើតចេញពីមូលហេតុចម្បងៗដូចខាងក្រោមៈ

➢ **ការបំពុលពីយានយន្ត**

យើងសង្កេតឃើញថានៅក្នុងក្រុងកំពង់ចាម តម្រូវការយានយន្តច្រើន និងក្នុងការធ្វើដំណើរក៏ច្រើនដែលជាហេតុនាំឱ្យកម្រិតឧស្ម័នពុលដែលត្រូវបានបញ្ចេញទៅបរិយាកាសខ្ពស់។ លើសពីនេះនៅក្នុងប្រទេសកម្ពុជាប្រជាជនភាគច្រើនប្រើប្រាស់នូវយានយន្តចាស់ៗ ដែលនាំចូលពីប្រទេសដទៃដែលវាបញ្ចេញផ្សែងពុលទៅក្នុងបរិស្ថានច្រើនជាងយានយន្តថ្មី។

➢ **ការបំពុលដោយធូលី**

ធូលី ជាមូលហេតុដែលបណ្តាលឱ្យមានការបំពុលខ្យល់ផងដែរ។ សង្កេតឃើញថាក្នុងក្រុងកំពង់ចាមកត្តាចម្បងនៅក្នុងការធ្វើឱ្យមានធូលីនោះ គឺមកពីការដឹកជញ្ជូនសម្ភារៈសំណង់ ដោយមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។ មួយវិញទៀតការទុកដាក់សម្ភារៈសំណង់ទាំងនោះមិនបានល្អ ដូចជាការដាក់សម្ភារៈនៅតាមចិញ្ចើមផ្លូវ បានធ្វើឱ្យធូលីដីទាំងនោះហើរចូលក្នុងបរិយាកាសដែលយើងអាចឃើញជាក់ស្តែងនៅតាមការដ្ឋានសំណង់ មិនតែប៉ុណ្ណោះធូលីដែលជាប់តាមកង់យានយន្តក៏ជាមូលហេតុមួយបណ្តាលឱ្យមានធូលីដីផងដែរ។

➢ **ការបំពុលដោយចំហេះអូស ធ្យូង**

ការប្រើប្រាស់អូសធ្យូង ជាប្រភពថាមពលចម្អិនអាហារ គឺជាទំនៀមទម្លាប់មួយរបស់ប្រជាជនខ្មែរជាពិសេសនៅតាមទីជនបទជាក់ស្តែងនៅក្រុងកំពង់ចាមក៏ឃើញនៅមានការប្រើប្រាស់ថាមពលអូស ធ្យូងផងដែរ។ ប៉ុន្តែការប្រើប្រាស់អូស ធ្យូងនេះមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន។ ដោយនៅក្នុងចំហេះអូស ធ្យូង បានបង្កើតនូវឧស្ម័នកាបូនិច និងឧស្ម័នកាបូណាត រួមទាំងឧស្ម័នពុលជាច្រើនទៀតចូលក្នុងបរិស្ថាន។

❖ **វិធានការនៃការការពារការបំពុលខ្យល់**

នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេងមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ដូចជា ការរៀបចំនូវសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពខ្យល់ ស្តង់ដារគុណភាពខ្យល់បរិយាកាស និងខ្យល់ក្នុងអគារស្តង់ដារនៃការបញ្ចេញផ្សែង ចំហាយឧស្ម័ន សំឡេង រំញ័រ ពីប្រភពចល័ត និងប្រភពអចល័ត និងស្តង់ដារសារធាតុបំពុលបរិស្ថាន ដែលមានផ្ទុកនៅក្នុងសារធាតុឥន្ធនៈផូស៊ីល ក៏ដូចជាត្រួតពិនិត្យមធ្យោបាយគ្រប់គ្រង ឬបរិក្ខាប្រព្រឹត្តកម្មផ្សែង ចំហាយឧស្ម័ន

សំឡេង រំញ័រនៅតាមទីតាំង ឬសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មផ្សេងៗ។[៤៩] ភ្ជាប់ជាមួយគ្នានេះផង ដែលការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុ បំពុលខ្យល់ និងសំឡេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៥០] ចំណែកការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័នពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថានដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[៥១]

❖ **មូលហេតុនាំឱ្យមានការបំពុលដី និងវិធានការ**

ការបំពុលដី គឺត្រូវបានកំណត់ថាជាការសឹករិចរិល ឬការបំផ្លាញផ្ទៃដី និងដីដែលជាលទ្ធផលនៃការកើតចេញពីសកម្មភាពរបស់មនុស្ស។ មូលហេតុនៃការបំពុលដី គឺជាបញ្ហាធំមួយនៅជុំវិញពិភពលោកហើយបណ្តាលមកពីកត្តាផ្សេងៗគ្នា និងបុព្វហេតុចម្បងមួយចំនួនដូចខាងក្រោម៖

➢ **សកម្មភាពធ្វើកសិកម្ម**

ជាការពិតណាស់ ការធ្វើកសិកម្មត្រូវបានគេរកឃើញថាជាមូលហេតុផ្ទាល់ ប្រសិនបើការកាប់បំផ្លាញព្រៃឈើ ៨០(%)ភាគរយនៅទូទាំងពិភពលោក។ ភាគច្រើននៃផ្ទៃដីកសិកម្មនេះត្រូវបាន ទាមទារដើម្បីដាំដំណាំសម្រាប់ចំណីសត្វ ជាពិសេសគោ ក្របីសម្រាប់ឧស្សាហកម្មសាច់។ ម៉្យាងវិញទៀតការកើនឡើងនៃកំណើនប្រជាជនក្នុងពិភពលោក គឺការកើនឡើងនូវតម្រូវការសម្រាប់ការផ្គត់ផ្គង់ស្បៀងអាហារ ដែលជាមូលហេតុកំពុងបណ្តាលឱ្យព្រៃឈើ និងវាលស្មៅត្រូវបានប្តូរទៅជាដីស្រែចំការ ការដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជាដង្កូវ និងសត្វល្អិតជាដើម។ ការប្រើជី និងថ្នាំសម្លាប់សត្វល្អិតជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ ជាងនេះទៅទៀតកសិដ្ឋានចិញ្ចឹមសត្វជ្រូកបង្កើតឱ្យមានលាមកនិងទឹកនោមដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ហើយជ្រាបចូលក្នុងដី និងបំពុលទឹកផងដែរ។

➢ **ការចាក់សំរាម**

ការរំលោភបំពានបរិស្ថានធំបំផុតប្រកបទៅដោយកាកសំណល់ពុល ដែលបានបណ្តាលឱ្យមានការរលូតកូន ជំងឺសរសៃប្រសាទ ជំងឺមហារីក និងចំនួននៃការខូចទ្រង់ទ្រាយពីកំណើត និងការខូចទ្រង់ទ្រាយរបស់មនុស្សមុនពេលត្រូវបានគេរកឃើញ។ ហើយចំពោះអង្គធាតុរាវដែលចេញពីសំរាម គឺជាទឹករំអិលរាវដែលមានសារធាតុពុលខ្ពស់ផ្ទុកទៅដោយសារធាតុគីមីជាច្រើន ហើយក៏នាំឱ្យប៉ះពាល់ដែលបានជះឥទ្ធិពលអាក្រក់ដល់បរិស្ថានជាមួយ នឹងភាវរស់គ្រប់ប្រភេទ។

---

[៤៩] ដកស្រង់ពីគេហទំព័រ https://www.moe.gov.kh/ ចូលមើលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

[៥០] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា១៧

[៥១] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា១៨

➢ **សកម្មភាពធ្វើឧស្សាហកម្ម**

សកម្មភាពឧស្សាហកម្មឧស្សាហ៍បញ្ចេញកាកសំណល់ពុល និងវត្ថុធាតុដើមទៅលើដី ឬបរិយាកាស ដែលពួកគេតាំងនៅលើដី។ នៅក្នុងក្រុងកំពង់ចាមផ្ទាល់ដោយសង្កេតឃើញថាមានការប្រើប្រាស់នូវសារធាតុគីមី មិនត្រឹមត្រូវទៅលើដំណាំកសិផលសារធាតុគីមីទាំងអស់នោះ ជ្រៀបចូលទៅក្នុងដីដែលធ្វើឱ្យមានផលប៉ះពាល់ ទៅលើគុណភាពដី។ ផ្ទុយទៅវិញបើការប្រើប្រាស់សារធាតុគីមីតាមការណែនាំត្រឹមត្រូវ និងមិនបណ្ដាលឱ្យមាន ផលប៉ះពាល់ដល់គុណភាពដីនោះឡើយ។

❖ **វិធានការការពារពីការបំពុលដី**

- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសំណល់រឹងទៅលើដី
- ត្រូវធ្វើការរៀបចំ គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ប្រកបដោយប្រសិទ្ធភាព និងមិនប៉ះពាល់ដល់បរិស្ថាន
- ការកំណត់ប្រភេទ ឬកម្រាស់ ឬទំហំនៃថង់ប្លាស្ទិក។ អនុក្រឹត្យស្ដីពី ការគ្រប់គ្រងថង់ប្លាស្ទិក បានកំណត់ ហាមឃាត់ការនាំចូល ការផលិតក្នុងស្រុក ការប្រើប្រាស់ និងចែកចាយនូវថង់ប្លាស្ទិក ស្ដើងមានដៃយួរគ្រប់ប្រភេទលើកលែងតែថង់ផ្លាស្ទិកមានកម្រាស់ចាប់ពី ០,០៣មីលីម៉ែត្រឡើងទៅ និងមានរង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥សង់ទីម៉ែត្រ ឬ ១០អ៊ីងឡើងទៅ
- ធ្វើការផ្សព្វផ្សាយនឹងលើកទឹកចិត្តឱ្យសាធារណៈជនចូលរួមក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា
- រាល់លំនៅឋាន ផ្សារទំនើប កន្លែងកម្សាន្ត និងស្ថាប័នទាំងអស់ មានកាតព្វកិច្ចទុកដាក់ និងរៀបចំ បែងចែកសំណល់រឹងដាច់ដោយឡែកពីសំណល់ផ្សេងៗទៀតតាមគោលការណ៍របស់ក្រសួងវិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោះបំបែក ធ្វើប្រតិកម្ម ឬបោះបង់ចោល សំណល់រឹង ត្រូវអនុវត្តន៍ឱ្យបាន ត្រឹមត្រូវ តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ដែលបង្កឱ្យមានផលប៉ះពាល់ ឬគ្រោះថ្នាក់ដល់ សុខភាពសាធារណៈ និងបរិស្ថាន។ ឧទាហរណ៍ដូចជា សំណល់អាគុយ សំណល់ថ្មពិល ឬសំណល់ បរិក្ខាអគ្គិសនី និងអេឡិចត្រូនិច។[៥២]

[៥២] អនុក្រឹត្យស្ដីពីការគ្រប់គ្រងថង់ប្លាស្ទិច, លេខ១៦៨ អនក្រ.បក, ១០ តុលា ២០១៧, មាត្រា១៤

❖ **ការបំពុលដោយសំឡេង និងវិធានការការពារដោយបំពុលសំឡេង**

សំឡេង គឺជាផ្នែកមួយដែលធ្វើឱ្យមានការបំពុលទៅដល់បរិស្ថាន។ ក្នុងនោះផងដែរបានសង្កេតឃើញថាក្រុងកំពង់ចាមជាក្រុងមួយដែលទទួលរងនូវការបំពុលសំឡេង ដោយការបំពុលសំឡេងនោះបណ្តាលមកពីកត្តាមួយចំនួនដូចជាយានយន្ត ក្លឹបកំសាន្ត រោងចក្រ និងការសាងសង់ការដ្ឋាន ឬសំណង់អាគារជាដើម។

យោងតាមអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ការបំពុលដោយសំឡេងមានប្រភពពីរគឺ៖

❖ **ប្រភពចល័ត** ជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន យន្តហោះ នាវាដឹកជញ្ជូន គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។

❖ **ប្រភពដោយអចល័ត** ជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍រួមមានដូចជា រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រទភេទ។[៥៣]

➢ **ការបំពុលសំឡេងដោយប្រភពចល័តក្នុងក្រុងកំពង់ចាម**

ការបំពុលសំឡេងដោយប្រភពចល័តនេះ គឺសំដៅទៅលើការបំពុលដោយសំឡេងចេញពីយានយន្តនៅលើផ្លូវសាធារណៈ។ ដោយសារតែកត្តាយាន្តយន្តមួយចំនួននៅក្នុងក្រុងកំពង់ចាម ហើយក្រុងកំពង់ចាម ជាក្រុងមួយដែលកំពុងតែមានការអភិវឌ្ឍ និងទទួលបានការវិនិយោគដូចជា ផ្ទះល្វែងជាដើម ដែលជាកត្តាមួយតម្រូវឱ្យមានការដឹកជញ្ជូនធ្ងន់ៗ កត្តានេះហើយដែលនាំឱ្យសំឡេងក៏មានការកើនឡើងដែរ។ ដែលនាំឱ្យការបំពុលដោយសំឡេងក៏កាន់តែខ្លាំងផងដែរ។

➢ **ការបំពុលសំឡេងដោយប្រភពអចល័តក្នុងក្រុងកំពង់ចាម**

ចំពោះការបំពុលសំឡេងដោយប្រភពអចល័ត សំដៅទៅលើប្រភពបំពុលដែលចេញពីទីតាំងជាក់លាក់ណាមួយដែលមិនមានបំលាស់ទីដូចប្រភពចល័តនោះទេ។ ហើយប្រភពបំពុលអចល័តក្នុងក្រុងកំពង់ចាមអាចបណ្តាលមកពីរោងចក្រ សហគ្រាស កន្លែងកម្សាន្ត កន្លែងសិប្បកម្ម ការដ្ឋានសំណង់ជាដើម។ ជាក់ស្តែងសំឡេងបុកគ្រឹះនៅការដ្ឋានសំណង់ ឬតន្ត្រីនៅក្លឹបកំសាន្តរាត្រី ផាប់ ក្លឹបរាំកំសាន្ត ជាដើមកំពុងតែធ្វើឱ្យមានការបំពុលជារៀងរាល់ថ្ងៃ។

[៥៣] អនុក្រឹត្យលេខស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា៣

❖ **វិធានការការពារដោយបំពុលសំឡេង**

ដោយយោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង បានកំណត់អំពីការត្រួតពិនិត្យនូវសំឡេងរំខានពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៥៤] ចំពោះត្រួតពិនិត្យនូវការរំខានដោយសំឡេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[៥៥]

❖ **ការបំពុលដោយកាកសំណល់រឹង រាវ និងវិធានការ**

សំណល់រឹង សំដៅលើសារធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល។ ឯសំណល់រាវ សំដៅទៅលើវត្ថុរាវដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបីជាបានធ្វើប្រតិកម្ម ឬមិនបានធ្វើប្រតិកម្មក្តី។ ទន្ទឹមជាមួយគ្នានេះផងដែរ ប្រភពបំពុលសំណល់ទាំងអស់នេះ ចេញប្រភពមកពីលំនៅឋាន អគាររដ្ឋបាលសាធារណៈ បរិវេណមធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបានបញ្ចេញសំណល់រឹង រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់សាធារណៈ។

❖ **វិធានការគ្រប់គ្រងកាកសំណល់រឹង រាវ**

តាមប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅថ្នាក់ខេត្ត ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយដោយរាប់បញ្ចូលទាំងការប្រមូលការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចដែលពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ រាជធានី ខេត្ត ក្រុង ប្រកបដោយប្រសិទ្ធិភាពទូទាំងប្រទេស។ ប្រកាសអន្តរក្រសួងលេខ ៨០ផ្តល់ទៅឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ការដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ដើម្បីធានានូវសោភ័ណភាព និងបរិស្ថាន
- ដាក់ស្លាកហាមឃាត់ចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្នឱ្យបានសមរម្យ ដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម

---

[៥៤] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា១៧

[៥៥] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ៤២ អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា១៨

- ប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងទៅបោះចោលឱ្យបានទៀងទាត់ នៅទីលានចាក់សំរាម ដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានការសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនានាត្រូវអប់រំ និងផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណៈជន អំពីការទុកដាក់សំរាម សំណល់រឹងតាមរយៈវិធីសាស្ត្រ ប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែជំរុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន
- មន្ទីរបរិស្ថានខេត្ត ក្រុង និងការិយាល័យបរិស្ថានស្រុក ខណ្ឌត្រូវដើរតួនាទីជាសេនាធិការឱ្យអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមបង្កើតផែនការសកម្មភាពក្នុងការប្រមូលការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាមដោយត្រូវសហការ និងតាមដានការអនុវត្តផែនការទាំងនោះផងដែរ។ ត្រូវរាយការណ៍អំពីការអនុវត្តផែនការសកម្មភាពខ្លួន អំពីការប្រមូល ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាម ដោយត្រូវធ្វើរបាយការណ៍នេះទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានព្រមទាំងក្រសួងដែលមានការពាក់ព័ន្ធទៀតផង។[៥៦]

ដោយយោងតាមអនុក្រឹត្យលេខ១១៣ ដែលទទួលបានការអនុម័តកាលពីខែសីហា ឆ្នាំ២០១៥ បានកំណត់អាណត្តិកាន់តែច្បាស់លាស់ និងមានភាពប្រសើរដល់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ ដោយអនុក្រឹត្យនេះមានគោលបំណង នៅក្នុងការពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា លើការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជនប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារនៃការគ្រប់គ្រងសំរាមសំណល់រឹង ទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌកំណត់រកវិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាមសម្រាប់សំណល់រឹងទីប្រជុំជន លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។[៥៧]

---

[៥៦] ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងថ្នាក់ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា, លេខ៨០, ២៥ កុម្ភៈ ២០០៣

[៥៧] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣, ២៧ សីហា ២០១៥, មាត្រា២

## ២.២. ផលវិបាកក្នុងការរៀបចំក្រុងកំពង់ចាម

ការរៀបចំក្រុងនីមួយៗ តែងតែជួបប្រទះនឹងបញ្ហាជាច្រើន ដូចជាតម្រូវការខ្ពស់ទាំងសម្ភារៈ និងប្រភពធនធានដទៃទៀត។ ឧទាហរណ៍ ជាក់ស្តែងដើម្បីសាងសង់អគារមួយបានគេត្រូវការឧបករណ៍ និងសម្ភារៈសំណង់ជាច្រើន ព្រោះការធ្វើអគារមានទំហំធំ ជាពិសេសវាទាមទារនូវទំហំពលកម្មច្រើន ក៏ដូចជាប្រាក់ឈ្នួលសម្រាប់កម្មករដូចគ្នា។ លើសពីនេះដើម្បីឱ្យសំណង់អគារអាចទ្រទ្រង់បានល្អ លុះត្រាតែមានការគណនាបានច្បាស់លាស់ និងការសាងសង់ត្រូវទៅតាមមាត្រដ្ឋានត្រឹមត្រូវ។

ជាការពិតណាស់សម្រាប់ការរៀបចំក្រុងកំពង់ចាមក៏មានប្រឈមមុខនឹងបញ្ហាទាំងនេះផងដែរ ហើយកត្តាដែលជាបញ្ហាប្រឈមនោះរួមមាន៖

### ២.២.១. ធនធានមនុស្ស

ផ្នែកធនធានមនុស្សជាកត្តាចម្បងដែលមិនអាចខ្វះបាន ទោះបីជាបច្ចុប្បន្នកាន់តែទំនើប ដោយមានការប្រើប្រាស់គ្រឿងយន្តជំនួសកម្លាំងមនុស្សពិតមែន ក៏នៅតែមានការគ្រប់គ្រងពីមនុស្សដដែល។ ម៉្យាងទៀតធនធានមនុស្សនៅក្នុងក្រុងកំពង់ចាមមានការខ្វះខាត ដោយសារតែការធ្វើចំណាកស្រុកទៅកាន់ទីក្រុង និងការចាកចេញទៅធ្វើការនៅក្រៅស្រុក។ ដោយហេតុថាកត្តាជីវភាពមានការរាំងស្ទះដល់ការរស់នៅរបស់ពួកគាត់ ជាមូលហេតុបណ្តាលឱ្យពួកគាត់ព្យាយាមស្វែងរកលំនៅថ្មីដែលអាចទទួលយកបាន។ បញ្ហានេះជាកត្តា ប្រឈមក្នុងការរៀបចំក្រុងកំពង់ចាម។ បញ្ហាមួយទៀតដ៏សំខាន់ដែលបង្កផលលំបាកដល់គម្រោងការអភិវឌ្ឍមួយកម្រិតទៀតនោះ គឺកង្វះសមត្ថភាព ចំណេះ ជំនាញ និងបច្ចេកទេស គឺមិនទាន់ពេញលេញតាមតម្រូវការជាក់ស្តែងនោះទេ ដូច្នេះហើយបានជាបញ្ហាធនធានមនុស្សជាកត្តាដែលជះផលប៉ះពាល់ដល់ការរៀបចំក្រុង។

### ២.២.២. កង្វះគម្រោងថវិកា

ជាក់ស្តែងប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងមិនទាន់រីកចម្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួននោះទេ ដោយហេតុថាប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើន ជាពិសេសសង្គ្រាមផ្ទៃក្នុងដែលអូសបន្លាយអស់រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ក្រោយថ្ងៃរំដោះរាជរដ្ឋាភិបាលបានព្យាយាមអភិវឌ្ឍន៍ប្រទេសរហូតបានដល់មកបច្ចុប្បន្ន។ បើក្រឡេកមើលគម្រោងអភិវឌ្ឍន៍នីមួយៗវិញ គឺត្រូវការចំណាយទុនច្រើន ហើយជាញឹកញាប់ប្រទេសកម្ពុជាតែងតែទទួលជំនួយមានសំណង និងឥតសំណងជាច្រើនពីបណ្តាប្រទេសផ្សេងៗ។

ដើម្បីដំណើរការរៀបចំក្រុងបាន លុះត្រាតែមានការដាក់សំណើទៅថ្នាក់ជាតិ និងរងចាំការអនុញ្ញាតកញ្ចប់ថវិកាជាតិដែលផ្តល់សម្រាប់ការអភិវឌ្ឍ។ ដូចនេះប្រសិនបើខាងថ្នាក់ជាតិអនុញ្ញាត និងភ្ជាប់មកជាមួយនូវកញ្ចប់ថវិកាវាមិនជាបញ្ហានោះទេ ប៉ុន្តែផ្ទុយមកវិញបើគម្រោងត្រូវចំណាយច្រើនលើសពីលទ្ធភាពរបស់រដ្ឋច្បាស់ណាស់គម្រោងនោះនឹងត្រូវអូសបន្លាយ ដោយរងចាំការផ្តល់ជំនួយពីប្រទេសដទៃ។

### ២.២.៣. កង្វះបច្ចេកទេស

ដោយសារប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍន៍ ដូច្នេះហើយទើបធ្វើឱ្យការរៀបចំក្រុងមានផលវិបាកដោយមូលហេតុខ្វះបច្ចេកទេស និងមិនទាន់មានឧបករណ៍ទំនើបក្នុងការសាងសង់ ដូចជារៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ជាដើម។ ដោយសារតែហេតុផលនេះហើយទើបធ្វើឱ្យសំណង់ភាគច្រើននៅប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់មិនត្រឹមតែកង្វះនូវឧបករណ៍ប៉ុណ្ណោះទេស្របពេលដែលប្រទេសកម្ពុជាទើបតែងើបពីសង្គ្រាមប៉ុន្មានសតវត្សន៍ចុងក្រោយធ្វើឱ្យបាត់បង់នូវបុគ្គលឆ្នើម ក៏ដូចជាអ្នកមានចំណេះដឹងជាច្រើន។ ជាហេតុនាំឱ្យបច្ចុប្បន្នមានការទាមទារនូវបុគ្គល ដែលមានជំនាញខ្ពស់ជាច្រើននៅក្នុងការអភិវឌ្ឍ ហើយដោយសារជំនាញបច្ចេកទេសក្នុងស្រុកនៅមានកម្រិតនៅឡើយ ទើបបណ្តាលឱ្យមាននូវតម្រូវការអ្នកបច្ចេកទេស ជាការពិតវិស័យសំណង់ក្នុងពេលបច្ចុប្បន្នមិនត្រឹមតែរីកចម្រើននោះទេ គឺគម្រោងសាងសង់នីមួយៗកាន់តែប្រណិត និងទំនើប ដូច្នេះវិស្វករដែលទើបតែចាប់ផ្តើមការងារ មិនអាចកាន់កាប់ការងារសំខាន់ៗនោះទេ លុះត្រាតែជាវិស្វករអាជីព ដែលមានបទពិសោធន៍ការងារច្រើនឆ្នាំ ទើបអាចទទួលឱកាសក្នុងការកាន់គម្រោងការនោះ។ ហើយបញ្ហានេះ គឺជាបញ្ហាចោទដែលទាមទារឱ្យមានវិស្វករមកពីបរទេសដែលគេមានជំនាញ និងការយល់ដឹងខ្ពស់ជាងវិស្វករនៅក្នុងស្រុក ទើបប្រឡូកក្នុងការងារដែលមិនមែនជាវិស្វករអាជីពនោះទេ។ ដោយក្រឡេកទៅមើលបច្ចុប្បន្នភាពរបស់ក្រុងកំពង់ចាមវិញ ក៏នៅមានការកង្វះបច្ចេកទេសខ្វះខាតនៅឧបករណ៍ទំនើប និងខ្វះអ្នកបច្ចេកទេសផងដែរ។

### ២.២.៤. កង្វះការសហការពីប្រជាពលរដ្ឋ

ជាចាំបាច់សកម្មភាព ប្រជាជន និងការរួបរួម ការយោគយល់ អធ្យាស្រ័យពីសំណាក់ប្រជាពលរដ្ឋជាកម្លាំងជំរុញដ៏ខ្លាំងក្លាក្នុងការអភិវឌ្ឍ។ ជាក់ស្តែងប្រជាជនត្រូវសហការជាមួយអាជ្ញាធរនៅក្នុងមូលដ្ឋាន ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចផងដែរ ក្នុងប្រការផ្សេងៗទាក់ទងនឹងកិច្ចរៀបចំក្រុង។ ឧទាហរណ៍ ប្រសិនបើមានការពង្រីកទំហំផ្លូវដើម្បីសម្រួលចរាចរណ៍លើដងផ្លូវ ហើយច្បាស់ណាស់ថាការពង្រីកផ្លូវនេះ តែងតែប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅម្តុំនោះជាក់ជាមិនខាន ដូច្នេះអាជ្ញាធរត្រូវចុះសុំការសហការពីម្ចាស់លំនៅដ្ឋានដោយមានការចរចាពីការខូចខាតផ្សេងៗ ក៏ដូចជាសំណងការខូចខាតផងដែរ។ ហើយនៅក្នុងនាមជាម្ចាស់លំនៅដ្ឋានត្រូវយោគយល់ដល់រដ្ឋដែលព្យាយាមផ្តល់ប្រយោជន៍រួមក្នុងសហគមន៍នោះ។ ជាក់ស្តែងប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងកំពង់ចាមមួយចំនួនធំ គឺតែងតែចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន និងមានតែមួយចំនួនតូចប៉ុណ្ណោះដែលគាត់មិនចូលរួមសហការក្នុងការអភិវឌ្ឍ។

## ២.៣. ដំណោះស្រាយ

នៅក្នុងការរៀបចំក្រុងមួយ គឺតែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលស្របពេលផែនការអភិវឌ្ឍន៍ទាំងអស់នោះត្រូវការផ្នែកធនធានមនុស្ស ថវិកា និងបញ្ហាបច្ចេកទេសផ្សេងៗ ហើយនឹងត្រូវប្រើប្រាស់រយៈពេលវែង ដែលមានន័យថាគម្រោងត្រូវតែចំណាយដើមទុន និងប្រើពេលវេលាយូរ។

### ២.៣.១. ដំណោះស្រាយធនធានមនុស្ស

ធនធានមនុស្ស គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ក្នុងការអភិវឌ្ឍប្រទេស ហើយបច្ចុប្បន្ននេះប្រទេសកម្ពុជាបានកំពុងយកចិត្តទុកដាក់ជាខ្លាំង ក្នុងការជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជាមានធនធានគ្រប់គ្រាន់សម្រាប់បម្រើឱ្យវិស័យនានា ដែលកំពុងរីកចម្រើន។ ទោះជាយ៉ាងនេះក្តីជាទូទៅក៏គេសង្កេតឃើញមានបញ្ហាប្រឈមខ្លះដែរ ដែលជាឧបសគ្គក្នុងវិស័យធនធានមនុស្សនៅប្រទេសកម្ពុជា។

ចំពោះបញ្ហាប្រឈមនៅក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សមានដូចជា៖

- ការគ្រប់គ្រង និងការអភិវឌ្ឍអាជីពមន្ត្រីរាជការ មិនទាន់ត្រូវបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព និងមិនទាន់មានការពិពណ៌នាអំពីមុខតំណែងឱ្យបានច្បាស់លាស់នៅឡើយ ដូចជាមានការបែងចែកការងារ ការរៀបចំការពិពណ៌នាមុខតំណែង
- ការគិតគូរអំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីដូចជាការរៀបចំការបណ្តុះបណ្តាលទៅតាមមុខតំណែង កំណត់តម្រូវការនៃការបណ្តុះបណ្តាល ការរៀបចំថវិកាសម្រាប់ការបណ្តុះបណ្តាល
- ការជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងស្របតាមតម្រូវការរបស់ក្រសួងស្ថាប័ន
- ការពង្រាយមន្ត្រី តាមជំនាញ និងទីកន្លែងការងារ
- ការវាយតម្លៃគុណផលរបស់មន្ត្រី
- ការលើកទឹកចិត្តមន្ត្រី ដូចជាបរិយាកាសការងារ ការឡើងថ្នាក់នឹងឋានន្តរសក្តិ ការឈប់សម្រាកប្រាក់បៀវត្ស
- ឥរិយាបថ និងវិន័យរបស់មន្ត្រីរាជការ។[៥៩]

### ២.៣.២. ដំណោះស្រាយគម្រោងថវិកា

ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់បានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកានោះទេ ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង

[៥៩] របាយការណ៍ស្តីពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា

ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួន ដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តសាមី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌមិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យ និងអនុម័តថវិការួច មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបថវិកានេះនៅតាមខេត្តនីមួយៗ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ថវិកាក្រុងត្រូវគ្រោងបញ្ចូលថវិកាសង្កាត់ ដែលជាថវិកាបានពីការបែងចែក និងផ្ទេរពីមូលនិធិឃុំ សង្កាត់ ព្រមទាំងចំណូលផ្ទាល់នៅមូលដ្ឋាន។ អភិបាលនៃគណៈអភិបាលក្រុងត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់ដល់រដ្ឋបាលសង្កាត់នីមួយៗ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។[៥៩]

### ២.៣.៣. ដំណោះស្រាយកង្វះបច្ចេកទេស

បច្ចុប្បន្នប្រទេសកម្ពុជា មានការខ្វះខាតអ្នកជំនាញបច្ចេកទេស ហើយកង្វះខាតទាំងអស់នេះក៏ព្រោះតែប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ទាំងវិស័យឧស្សាហកម្ម ទាំងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា និងសេវាកម្មផ្សេងៗទៀត។ ការអភិវឌ្ឍទាំងអស់នេះ គឺចាំបាច់ត្រូវការអ្នកជំនាញបច្ចេកទេសដើម្បីជួយគាំទ្រនៅក្នុងការអភិវឌ្ឍគ្រប់វិស័យទាំងអស់។

យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែប្រទេសកម្ពុជាឱ្យក្លាយ ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ដោយប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ ៤គឺ៖

- **យុទ្ធសាស្ត្រទី១** កៀងគរ និងទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស និងវិនិយោគទុនឯកជននៅក្នុងស្រុកដោយផ្តោតលើឧស្សាហកម្មធំៗ ការអភិវឌ្ឍ និងការពង្រីកទីផ្សារ និងការអភិវឌ្ឍការផ្ទេរបច្ចេកវិទ្យា
- **យុទ្ធសាស្ត្រទី២** អភិវឌ្ឍន៍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម
- **យុទ្ធសាស្ត្រទី៣** ការកែលម្អបរិស្ថាននិយតកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង

[៥៩] សៀវភៅ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥, ទំព័រទី១០-១១

- **យុទ្ធសាស្ត្រទី៤** អភិវឌ្ឍន៍ធនធានមនុស្ស បណ្តុះបណ្តាលជំនាញ ការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ប្រព័ន្ធដឹកជញ្ជូន ឡូជីស្ទីក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត សេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។[៦០]

### ២.៣.៤. ដំណោះស្រាយការសហការពីប្រជាពលរដ្ឋ

ជាការពិតណាស់រាជរដ្ឋាភិបាល បានព្យាយាមសម្រួលភាពលំបាកចំពោះការរស់នៅប្រជាជន តាមរយៈការរៀបចំអភិវឌ្ឍន៍ខេត្ត ក្រុង ស្រុក ដោយធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ជាចាំបាច់សកម្មភាពប្រជាជន និងការប្រមូលយោគយល់ អធ្យាស្រ័យពីប្រជាពលរដ្ឋជាកត្តាមួយជំរុញក្នុងការអភិវឌ្ឍ។ ប្រជាពលរដ្ឋត្រូវតែមានការសហការជាមួយអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច និងមន្ត្រីជំនាញគ្រប់ប្រភេទក្នុងកិច្ចការរៀបចំក្រុង។

ជាក់ស្តែងតាមបច្ចុប្បន្នភាពរដ្ឋបាលក្រុងកំពង់ចាម ក៏ដូចជាមន្ត្រីដែលពាក់ព័ន្ធបានព្យាយាមពន្យល់ និងសម្របសម្រួលភាពលំបាក ដែលមានការប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅក្នុងក្រុងកំពង់ចាម។ តាមរយៈការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅក្នុងក្រុងកំពង់ចាម ដោយធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

[៦០] ដកស្រង់ពីគេហទំព័រ https://education.ams.com.kh/education-update/national/news/labor-official-cambodia-still-lacks-human-resources-technical-skills-while-in-high-demand/ ចូលមើលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅប្រធានបទខាងលើនេះ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុង ជាផ្នែកមួយដែលចាំបាច់ក្នុងការជំរុញឱ្យមានការអភិវឌ្ឍសម្រេចបានទិសដៅនៃភាពជោគជ័យ ដើម្បីផ្លាស់ប្តូរក្រុងមួយឱ្យក្លាយជាក្រុងដែលមានលក្ខណៈស្តង់ដារ។ យ៉ាងណាមិញដំណើរការរៀបចំក្រុងកំពង់ចាមបានដំណើរការយ៉ាងល្អប្រសើរ ដោយមានសកម្មភាពចូលរួមសហការពីប្រជាពលរដ្ឋជាមួយនឹងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដើម្បីដំណើរការអភិវឌ្ឍនៅក្នុងក្រុងកំពង់ចាម។

ជាការពិតណាស់ការរៀបចំក្រុងឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ជាកត្តាមួយដ៏សំខាន់ ដោយក្រុងកំពង់ចាមក៏បានចូលរួមចំណែកក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់។ ជាពិសេសបានបង្កើតនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដោយក្រុងកំពង់ចាមបានរៀបចំឱ្យមានប្រព័ន្ធលូ ផ្លូវថ្នល់ បង្គោលភ្លើងបំភ្លឺតាមដងផ្លូវ សួនច្បារសាធារណៈ បើទោះបីជាការកសាងហេដ្ឋារចនាសម្ព័ន្ធខ្លះនៅមិនទាន់បានសម្រេចជាលទ្ធផល។ ម្យ៉ាងទៀតរដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធបានគិតគូរពីសុវត្ថិភាពប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងកំពង់ចាម ដោយបានអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងធានាមិនឱ្យមានអំពើអសន្តិសុខកើតមាននៅក្នុងមូលដ្ឋាន។ រដ្ឋបាលក្រុងកំពង់ចាម និងមន្ត្រីជំនាញដែលពាក់ព័ន្ធបានចុះផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ អំពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ផ្សព្វផ្សាយអំពីការចូលរួមថែរក្សាបរិស្ថាន និងបានផ្សព្វផ្សាយអំពីការប្រើប្រាស់ចំណីផ្លូវសាធារណៈ ចំពោះអាជីវករប្រកបអាជីវកម្មតាមដងផ្លូវ ដែលបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងក្រុងកំពង់ចាម។

យ៉ាងណាមិញក្នុងការសិក្សា និងការស្រាវជ្រាវទៅលើប្រធានបទសារណាស្តីពី **ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងកំពង់ចាម ឆ្នាំ២០១៨ ដល់២០២៣** បានធ្វើឱ្យមានការយល់កាន់តែច្បាស់អំពីបុព្វហេតុ និងសារៈសំខាន់ដែលនាំឱ្យមានការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់របស់ក្រុងកំពង់ចាម។ ការរៀបចំនោះមិនត្រឹមតែធ្វើឱ្យក្រុងមានសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងភាពស្រស់ស្អាតនោះទេ គឺថែមទាំងធ្វើឱ្យក្រុងមានភាពទាក់ទាញមួយកម្រិតទៀតលើសពីនេះការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់បានធ្វើឱ្យក្រុងមានការអភិវឌ្ឍស្ទើរគ្រប់វិស័យទាំងអស់ និងព្រមទាំងបានផ្តល់នូវទំនុកចិត្តដល់ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខដុមរមនា និងមានភាពស៊ីវិល័យទៀតផង។

សរុបសេចក្តីមក យើងអាចសន្និដ្ឋានបានថាការរៀបចំក្រុង គឺពិតជាមានសារៈសំខាន់ណាស់ កាលណាបើការរៀបចំនោះបានស្របទៅតាមលក្ខណៈបច្ចេកទេសនគរូបនីយកម្ម និងប្លង់គោល ហើយត្រឹមត្រូវទៅតាមផែនការយុទ្ធសាស្ត្រនោះនាំឱ្យក្រុងមានសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ និងព្រមដោយមានការចូលរួមសហការពីប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងនឹងស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរមូលដ្ឋានក្នុងក្រុងផ្ទាល់តែម្តង។

# អនុសាសន៍

# អនុសាសន៍

ដោយយោងតាមការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះ និងពិនិត្យមើលតាមស្ថានភាពជាក់ស្តែងនៅក្នុងក្រុងកំពង់ចាម យើងសង្កេតឃើញមានការអភិវឌ្ឍ ការរីកចម្រើនដែលអាចកត់សម្គាល់រួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ បរិស្ថាន និងសំណង់ជាច្រើន។ ទោះបីជាមានការអភិវឌ្ឍយ៉ាងនេះក្តីក៏នៅមានបញ្ហាមួយចំនួនទៀតដែលអាជ្ញាធរក្រុងបាននឹងកំពុងអនុវត្តន៍ហាក់បីដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយនោះទេ ក្នុងការទប់ស្កាត់នៅបញ្ហាដែលកើតមានឡើងជាយូរមកហើយនោះ ដែលអាចបង្កជាផលលំបាកខ្លះសម្រាប់ការអភិវឌ្ឍ ប៉ុន្តែទោះជាយ៉ាងនេះក្តីបញ្ហាទាំងអស់នោះត្រូវបានរដ្ឋបាលក្រុងកំពង់ចាម ក៏ដូចជាថ្នាក់ដឹកនាំរបស់រដ្ឋាភិបាលបានយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យការអភិវឌ្ឍបានដំណើរការយ៉ាងរលូនជាមួយនឹងការខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍក្រុងផងដែរ។

ដើម្បីចូលរួមដោះស្រាយបញ្ហាខាងក្រោមនេះ ខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញមតិដូចតទៅៈ

- ស្នើសុំអាជ្ញាធរពាក់ព័ន្ធចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការវេចខ្ចប់ទុកដាក់សំណល់រឹងរាវ ដើម្បីរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ និងជៀសវាងការសាយភាយក្លិនមិនល្អ និងបញ្ហាកកស្ទះប្រព័ន្ធលូ
- ស្នើសុំឱ្យអាជ្ញាធរមានការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថានក្នុងក្រុងរួមមានដូចជា ការគ្រប់គ្រងកាកសំណល់ ការប្រមូល ការដឹកជញ្ជូន និងការស្តុកសំរាមទុក
- ស្នើសុំអាជ្ញាធរធ្វើការទប់ស្កាត់នូវការប្រើប្រាស់ចំណីផ្លូវសាធារណៈ សម្រាប់ធ្វើអាជីវកម្មរបស់ខ្លួនដែលប៉ះពាល់សោភ័ណភាព សណ្តាប់ធ្នាប់ ក៏ដូចជារបៀបរៀបរយនៅក្នុងក្រុងកំពង់ចាម
- បញ្ហាអសន្តិសុខ អំពើចោរកម្ម ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធក្នុងក្រុងកំពង់ចាម សូមមេត្តាពង្រឹងច្បាប់ និងផ្សព្វផ្សាយព្រមទាំងអនុវត្តន៍នូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពឱ្យបានតឹងរឹងជាទីបំផុត ដើម្បីធានាដល់សុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋ
- បង្កើនសមត្ថភាពចំណេះ និងជំនាញដល់បុគ្គលដែលមានភារកិច្ចទាក់ទងកិច្ចការ និងការអភិវឌ្ឍគម្រោងនីមួយៗតាមរយៈការបណ្តុះបណ្តាលអំពីបច្ចេកទេសស្របតាមស្តង់ដារអភិវឌ្ឍន៍ និងផ្តល់ឱកាសទៅធ្វើការសិក្សា ដើម្បីទទួលបានចំណេះដឹងផ្នែកស្ថាបត្យកម្ម និងបច្ចេកទេសផ្សេងៗ។

ទន្ទឹមនឹងការអភិវឌ្ឍនេះ សូមឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួម នៅក្នុងសកម្មភាពថែរក្សាការពារ បរិស្ថានអនាម័យ ដើម្បីឱ្យតំបន់នោះក្លាយជាតំបន់ដែលទទួលបានបរិស្ថានល្អប្រសើរ និងដើម្បីការរស់នៅដែលប្រកបទៅដោយផាសុខភាព អនាម័យ និងបរិស្ថានបៃតង សូមប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ទាំងអស់យកចិត្តទុកដាក់ និងបើកចិត្តទទួលយកការអប់រំពីថ្នាក់ដឹកនាំក្រុង សូមគោរពទៅតាមសេចក្តីប្រកាស ការណែនាំ ព្រមទាំងអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួន។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៤៤៥ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣
- អនុក្រឹត្យលេខ១១៩ អនក្រ.បក ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
- អនុក្រឹត្យលេខ២២ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិច ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩
- ប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងថ្នាក់ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣
- សេចក្តីណែនាំលេខ១៨ អយក.សណន ស្តីពីចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩
- សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧
- ផែនការណែនាំលេខ០២០ ផ.ក ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០
- របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងកំពង់ចាម, លេខ០០១/២៣ រ.ប.ក ប្រចាំឆ្នាំ២០២២
- របាយការណ៍ការិយាល័យផែនការ និងគាំទ្រសង្កាត់ លេខ០៤៣ ផ.ក.ក្រក.ច ប្រចាំឆ្នាំ២០២២

- របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា ឆ្នាំ២០១៨-២០២២
- របាយការណ៍ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍ក្រុងកំពង់ចាម ប្រចាំឆ្នាំ២០២០
- របាយការណ៍ស្តីពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា

## ២. សៀវភៅតែងនិពន្ធ

- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣
- សៀវភៅ ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០២០-២០២៤) ក្រុងកំពង់ចាម
- សៀវភៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ
- សៀវភៅ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធចរិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥

## ៣. គេហទំព័រផេបសាយ

- គេហទំព័រ https://www.mpwt.gov.kh/kh/press/32191
- គេហទំព័រ https://www.interior.gov.kh/report/detail/2325
- គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/140598-2019-11-24-09-06-53.html
- គេហទំព័រ https://sbm.news/articles/61d409ef19d3cbfafaf225ef
- គេហទំព័រ https://www.kampucheathmey.com/local-news/307147
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/water-pollution/
- គេហទំព័រ https://thmeythmey.com/m/?page=detail&id=58963
- គេហទំព័រ https://www.khsearch.com/qua/10411
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/air-pollution
- គេហទំព័រ https://www.moe.gov.kh/
- គេហទំព័រ https://education.ams.com.kh/education-update/national/news/labor-official-cambodia-still-lacks-human-resources-technical-skills-while-in-high-demand/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យលេខ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈ អភិបាលស្រុក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យលេខ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសម្លេង, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក,
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩

**ឧបសម្ព័ន្ធទី៤៖** ផែនការណែនាំលេខ០២០ ផ.ក ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីរដ្ឋបាលខេត្តកំពង់ចាម និងរដ្ឋបាលក្រុងកំពង់ចាម

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗនៅក្នុងរដ្ឋបាលក្រុងកំពង់ចាម និងសោភ័ណភាពក្រុងកំពង់ចាម

**ឧបសម្ព័ន្ធទី៣៖** សកម្មភាពរដ្ឋបាលក្រុងកំពង់ចាម

# ឧបសម្ព័ន្ធគតិយុត្ត

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

- ការអនុវត្តមុខងារ ភារកិច្ចថ្មីដែលបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត លើកលែងតែមុខងារ ភារកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលាខេត្ត ដែលបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្រៅពីភារកិច្ចដូចមានចែងខាងលើនេះ ទីចាត់ការនីមួយៗអាចបំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីគណៈអភិបាលខេត្ត។

ទីចាត់ការនីមួយៗ ត្រូវបំពេញកិច្ចការដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាជាធរមាន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីភារកិច្ច និងរបៀបរបបការងាររបស់ទីចាត់ការនានានៃសាលាខេត្ត។

**មាត្រា ៥៩.-**

ផ្អែកតាមតួនាទី ភារកិច្ចរបស់ទីចាត់ការនានានៃសាលាខេត្ត ដូចមានចែងក្នុងមាត្រា៥៨នៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយពីមានការឯកភាពពី គ.ជ.អ.ប. ត្រូវចេញប្រកាសបង្កើតការិយាល័យចំណុះទីចាត់ការនីមួយៗនៃសាលាខេត្ត និងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបការងាររបស់ការិយាល័យនីមួយៗនោះ។

**មាត្រា ៦០.-**

ក្រៅពីទីចាត់ការនិងការិយាល័យដូចមានចែងក្នុងមាត្រា៥៥និងមាត្រា៥៩នៃអនុក្រឹត្យនេះ គណៈអភិបាលខេត្តអាចស្នើទៅក្រុមប្រឹក្សាខេត្ត ដើម្បីបង្កើតទីចាត់ការឬការិយាល័យបន្ថែមទៀតតាមការចាំបាច់។

ទីចាត់ការឬការិយាល័យដែលបង្កើតបន្ថែមខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយទីចាត់ការឬការិយាល័យដែលតម្រូវឱ្យបង្កើតឡើងដោយអនុក្រឹត្យនេះឡើយ។

ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលខេត្តត្រូវលើកសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និង/ឬរៀបចំបែបបទក្នុងការបង្កើត ឬរំសាយ ឬកែសម្រួលទីចាត់ការ ឬការិយាល័យខាងលើនេះ។

## ជំពូកទី៣

## រដ្ឋបាលក្រុង

### ផ្នែកទី១

### ក្រុមប្រឹក្សាក្រុង

**មាត្រា ៦១.-**

ក្រុមប្រឹក្សាក្រុងនីមួយៗដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៦២.-**

ក្រុមប្រឹក្សាក្រុងនីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**មាត្រា ៦៣.-**

ក្រុមប្រឹក្សាក្រុង មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៦៤.-**

ក្រុមប្រឹក្សាក្រុងនីមួយៗ ត្រូវសម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសង្កាត់ និងសហគមន៍ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីកំណត់អំពីតម្រូវការជាអាទិភាពក្នុងការផ្ដល់សេវានិងការអភិវឌ្ឍ និងសំណើឬសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងក្រុងរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុង។

**មាត្រា ៦៥.-**

ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាក្រុងត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ នៅតាមសង្កាត់នានាក្នុងក្រុងរបស់ខ្លួន។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាសង្កាត់ទាំងអស់នៅក្នុងក្រុង តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀត តាមការសម្រេចពីក្រុមប្រឹក្សាក្រុង។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាក្រុងជម្រាបជូនក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានាអំពីសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង ក្នុងចន្លោះពេលពីវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយទៅវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់មួយ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សា ស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាក្រុងនីមួយៗ ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ។

គណៈអភិបាលក្រុង ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ ក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលក្រុង។ ចំពោះកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលក្រុងត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួន។ គណៈអភិបាលក្រុងត្រូវបញ្ជូនរបាយការណ៍ខាងលើនេះ មួយច្បាប់មករដ្ឋបាលខេត្ត ដើម្បីពិនិត្យនិងដោះស្រាយកិច្ចការទាំងឡាយណាដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរដ្ឋបាលខេត្ត។ ចំពោះកិច្ចការដែលពាក់ព័ន្ធសមត្ថកិច្ចដោះស្រាយរបស់ថ្នាក់ជាតិ គណៈអភិបាលខេត្តត្រូវធ្វើការប្រមូលផ្ដុំពីគ្រប់ក្រុង ដើម្បីធ្វើ

សេចក្តីរាយការណ៍មកក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាក្រុង ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។

**មាត្រា ៦៧.-**

កិច្ចប្រជុំក្រុមប្រឹក្សាក្រុង អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាក្រុងរបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាក្រុងកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

**មាត្រា ៦៨.-**

ក្រុមប្រឹក្សាក្រុង អាចចាត់ឱ្យគណៈកម្មាធិការណាមួយឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលក្រុងត្រូវដឹកនាំនាយករដ្ឋបាលសាលាក្រុងនិងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលក្រុងដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ការិយាល័យនានានៃសាលាក្រុង រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចដាក់ជូនក្រុមប្រឹក្សាពិនិត្យពិភាក្សា និងអនុម័ត។

គណៈអភិបាលក្រុង ត្រូវណែនាំនាយករដ្ឋបាលសាលាក្រុងឱ្យរៀបចំដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួចឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលក្រុង។

ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**មាត្រា ៦៩.-**

ប្រធានក្រុមប្រឹក្សាក្រុងក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុង លើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុងឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុង តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលក្រុង ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ៧០.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលក្រុងនិងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង

- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៧១.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុងត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា៧០នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួន នូវកិច្ចការផ្សេងៗទៀត រួមមាន :

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ឬហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលក្រុងអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនោះ
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវនិងការធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុងតាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលក្រុង
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។

**មាត្រា ៧២.-**

ក្រុមប្រឹក្សាក្រុង ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណី កិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត មិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

ក្នុងករណី កិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទនិងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តបាន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃ គ.ជ.អ.ប. ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ។

**មាត្រា ៧៣.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាក្រុងបានសម្រេចរួចហើយ គណៈអភិបាលក្រុងត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា ដូចមានចែងក្នុងមាត្រា៧០និងមាត្រា៧១នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាក្រុង ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលក្រុង ដើម្បីធានាថា គណៈអភិបាលក្រុងអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាក្រុង។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាក្រុងក្នុងការរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង។

**មាត្រា ៧៤.-**

ដីកាឬសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាសង្កាត់ ត្រូវស្ថិតក្រោមការពិនិត្យនីត្យានុកូលភាពរបស់ក្រុមប្រឹក្សាក្រុង។

ក្រុមប្រឹក្សាក្រុង ត្រូវធ្វើប្រតិភូកម្មដល់គណៈអភិបាលក្រុង ដើម្បីពិនិត្យនីត្យានុកូលភាពនេះ។

ក្នុងករណីពិនិត្យឃើញថាដីកាឬសេចក្ដីសម្រេចណាមួយរបស់ក្រុមប្រឹក្សាសង្កាត់ មិនស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលការណ៍ដែលសម្រេចដោយក្រុមប្រឹក្សាក្រុង ឬការសម្រេចឬការងារណាមួយដែលក្រុមប្រឹក្សាសង្កាត់បានធ្វើការសម្រេចហួសពីដែនសមត្ថកិច្ចដែលក្រុមប្រឹក្សាក្រុងបានធ្វើប្រតិភូកម្ម គណៈអភិបាលក្រុងត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរជូនដល់ក្រុមប្រឹក្សាសង្កាត់ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេចក្ដីសម្រេចជាក់លាក់ និងកិច្ចការជាក់លាក់ណាមួយឬមួយចំនួន ដែលក្រុមប្រឹក្សាសង្កាត់ធ្វើការសម្រេចឬធ្វើសកម្មភាពមិនសមស្រប។ ផ្អែកតាមការណែនាំនេះ ក្រុមប្រឹក្សាសង្កាត់ត្រូវកែតម្រូវសេចក្ដីសម្រេចឬសកម្មភាពរបស់ខ្លួនឱ្យបានសមស្របឡើងវិញក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានទទួលការណែនាំជាលាយលក្ខណ៍អក្សរពីគណៈអភិបាលក្រុង។

ក្នុងករណីក្រុមប្រឹក្សាសង្កាត់មិនអនុវត្តតាមការណែនាំខាងលើនេះ ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្ដីរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត ដើម្បីសម្របសម្រួលអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង

**មាត្រា ៧៥.-**

ក្រុមប្រឹក្សាក្រុង ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ។

**មាត្រា ៧៦.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាក្រុងអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឡើយ ។

ក្រុមប្រឹក្សាក្រុងអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលក្រុង ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលក្រុង ។

**មាត្រា ៧៧.-**

ក្រុមប្រឹក្សាក្រុង អាចតែងតាំងសមាជិកក្រុមប្រឹក្សាក្រុង អភិបាលក្រុង អភិបាលរងក្រុង តំណាងក្រុមប្រឹក្សាសង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សាក្រុង តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ សម្រាប់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាក្រុង ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាក្រុង អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលក្រុង ។

**មាត្រា ៧៨.-**

គណៈអភិបាលក្រុង អាចស្នើសុំក្រុមប្រឹក្សាក្រុងដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាក្រុងបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលក្រុង ។

**មាត្រា ៧៩.-**

ក្រុមប្រឹក្សាក្រុង ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានានិងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនេះ ។

**មាត្រា ៨០.-**

ក្រុមប្រឹក្សាក្រុង ត្រូវណែនាំឱ្យគណៈអភិបាលក្រុងផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាក្រុងបានបង្កើតឡើង។

**មាត្រា ៨១.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលក្រុង ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សាក្រុង។

ក្រុមប្រឹក្សាក្រុង អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុងតាមការចាំបាច់។

## ផ្នែកទី៣
## គណៈអភិបាលក្រុង

**មាត្រា ៨២.-**

ក្រុងនីមួយៗ ត្រូវមានគណៈអភិបាលក្រុងមួយដែលរួមមាន អភិបាលក្រុង អភិបាលរងក្រុង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៨៣.-**

អភិបាលក្រុង អភិបាលរងក្រុង មិនមែនជាសមាជិកក្រុមប្រឹក្សាក្រុងឡើយ។

**មាត្រា ៨៤.-**

គណៈអភិបាលក្រុង ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៨៥.-**

គណៈអភិបាលក្រុង មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាក្រុង និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ។

**មាត្រា ៨៦.-**

គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ

- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ក្រុង
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ការិយាល័យនិងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិក
  + វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
  + វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
  + កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។
- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់

– កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន។

**មាត្រា ៨៧.-**

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុងត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាក្រុង និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨៨.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៨៦និងមាត្រា៨៧នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលក្រុងត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលក្រុងរបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាក្រុងអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុងលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលក្រុងអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៨៩.-**

គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៩០.-**

គណៈអភិបាលក្រុង ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុងនិងអភិបាលរងក្រុង ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្ដីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលក្រុង អភិបាលរងក្រុង និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៩១.-**

អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្ដីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា៦៩នៃអនុក្រឹត្យនេះ។

អភិបាលក្រុង អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។

អភិបាលក្រុង ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង។

អភិបាលក្រុង មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្ដីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៩២.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង អភិបាលក្រុងមានភារកិច្ច :

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និង តម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួល តម្រង់ទិសការិយាល័យ អង្គភាព និង

ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាក្រុង។

- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យនិងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅក្នុងក្រុងរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួន ឬ ករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរនិងជាបន្ទាន់ទៅអភិបាលខេត្ត។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពសាមីប្រចាំនៅខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះឬអាចចាត់តាំងគណៈកម្មការឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុងដែលពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី។
- អភិបាលក្រុងមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

ដើម្បីធានាឱ្យអភិបាលក្រុងអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ត្រូវដាក់ជូនអភិបាលក្រុងដើម្បីពិនិត្យនិងផ្តល់យោបល់។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុងត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ត្រូវចម្លងជូនសាលាក្រុង។

**មាត្រា ៩៣.-**

អភិបាលក្រុងត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងក្រុង អំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងក្រុង។

អភិបាលក្រុង គឺជាប្រធានគណៈបញ្ជាការឯកភាពក្រុង ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានានិងសង្កាត់នៅក្នុងក្រុង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងក្រុង។

**មាត្រា ៩៤.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៩២និងមាត្រា៩៣នៃអនុក្រឹត្យនេះ អភិបាលក្រុងត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយខ្លួនក្នុងការងារខាងលើនេះ។

អភិបាលរងក្រុងដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលក្រុង។

អភិបាលក្រុង ត្រូវកោះប្រជុំគណៈអភិបាលតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលក្រុង សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ។

**មាត្រា ៩៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៩២និងមាត្រា៩៣នៃអនុក្រឹត្យនេះ អភិបាលក្រុងត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ៩៦.-**

អភិបាលក្រុងដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន។

ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលក្រុងក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារ តវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងអាចតម្រូវឱ្យអភិបាលក្រុងធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង។

ក្រុមប្រឹក្សាក្រុង អាចផ្តល់អនុសាសន៍និងការណែនាំដល់អភិបាលក្រុងអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

អភិបាលក្រុង ត្រូវទទួលយកអនុសាសន៍ និងការណែនាំនានាពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ។

**មាត្រា ៩៧.-**

ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងក្រុងមួយរូប

ឱ្យទទួលជាអភិបាលក្រុងស្ដីទី។

ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងក្រុងដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុង ត្រូវធ្វើជាអភិបាលក្រុងស្ដីទី។

ក្នុងករណីអភិបាលក្រុងស្ដីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្ដីទី និងត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលក្រុងស្ដីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុង នៅពេលដែលអភិបាលក្រុងមានវត្តមានវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្ដីណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។

**មាត្រា ៩៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្ដីណែនាំស្ដីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលក្រុង អភិបាលរងក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង។

## ផ្នែកទី៤
## នាយករដ្ឋបាលសាលាក្រុង

**មាត្រា ៩៩.-**

ក្រុមប្រឹក្សាក្រុងនិងគណៈអភិបាលក្រុង ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាក្រុង ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលក្រុង ដោយយោងតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង។

នាយករដ្ឋបាលសាលាក្រុង ត្រូវមាននាយករងរដ្ឋបាលសាលាក្រុងយ៉ាងច្រើនពីរ(០២)រូប ជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលក្រុង ដោយយោងតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង។

នាយករដ្ឋបាលសាលាក្រុង ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាក្រុង ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ១០០.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាក្រុង និងនាយករងរដ្ឋបាលសាលាក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៩៥.-**

ក្រុមប្រឹក្សាខេត្តត្រូវទំនាក់ទំនងសហប្រតិបត្តិការនិងពិគ្រោះយោបល់ជាមួយ គ.ជ.អ.ប. និងក្រសួង ស្ថាប័ននានាក្នុងការងារបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រងនិងការកៀរគរចំណូល ព្រមទាំងការពិនិត្យនិងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក រវាងថ្នាក់ជាតិ និងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវធានាឱ្យមានការពិគ្រោះយោបល់សមស្រប ជាមួយរដ្ឋបាលក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត សម្រាប់ជាមូលដ្ឋានក្នុងការពិគ្រោះពិភាក្សាជាមួយ គ.ជ.អ.ប. និងក្រសួង ស្ថាប័ននានាអំពីការងារខាងលើនេះ។

ផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប. ក្រុមប្រឹក្សាខេត្តត្រូវធានាធ្វើការសម្របសម្រួលជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ក្នុងខេត្ត ដើម្បីបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រងនិងការកៀរគរចំណូល ព្រមទាំងបុគ្គលិក ឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ រួមទាំងតំបន់ប្រជុំជននិងតំបន់ជនបទក្នុងខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវធានាថា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ក្នុងខេត្ត បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ។

**មាត្រា ១៩៦.-**

ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ ដើម្បីធានាថារដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំនិងរដ្ឋបាលសង្កាត់ បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ឬបានធ្វើប្រតិភូកម្ម ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងស្របតាមគោលនយោបាយរបស់ជាតិ។

ការធ្វើប្រតិភូកម្មនេះរួមមាន :

- ការវាយតម្លៃនិងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាទាំងនេះ
- ការណែនាំនិងសម្របសម្រួល គាំទ្រដល់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ក្នុងការអនុវត្តមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឱ្យស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ
- ត្រូវធានាថាក្រុង ស្រុកបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់ក្នុងក្រុងនិងឃុំ សង្កាត់ក្នុងស្រុក។

ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ក្រុង ស្រុក ឃុំនិងសង្កាត់ ឱ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យនេះ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប.។

ក្រុមប្រឹក្សាខេត្តត្រូវធ្វើប្រតិភូកម្មអំពីការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់គណៈអភិបាលខេត្ត

ដើម្បីអនុវត្តកិច្ចការប្រចាំថ្ងៃ។ ក្នុងការអនុវត្តការងារប្រចាំថ្ងៃ គណៈអភិបាលគឺជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ ព្រមទាំងការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំនិងសង្កាត់ក្នុងខេត្ត។

គណៈអភិបាលត្រូវស្នើសុំគោលការណ៍ណែនាំនិងធ្វើសេចក្ដីរាយការណ៍ អំពីការអនុវត្តតួនាទី ភារកិច្ចខាងលើនេះរៀងរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាខេត្តអាចកោះប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ ពិភាក្សាអំពីការគាំទ្រនិងការធ្វើប្រតិភូកម្មខាងលើនេះ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសដើម្បីកំណត់អំពីគោលការណ៍និងនីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មខាងលើនេះ។

**មាត្រា ១៩៧.-**

អភិបាលខេត្តក្នុងនាមគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន ជាអ្នកចុះហត្ថលេខាលើលិខិតបទដ្ឋានរដ្ឋបាលនានា ដើម្បីបម្រើឱ្យទំនាក់ទំនងដូចបានកំណត់ក្នុងមាត្រា១៩៦នៃអនុក្រឹត្យនេះ។

ឯកសារ លិខិតស្នាមពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលទៅរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់ ត្រូវបញ្ជូនទៅសាលាខេត្ត។

អភិបាលខេត្ត ត្រូវធានាបែងចែក និងបញ្ជូនឯកសារ លិខិតស្នាមខាងលើនេះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាដល់ថ្នាក់រដ្ឋបាល ឬបុគ្គលដែលពាក់ព័ន្ធ។

**មាត្រា ១៩៨.-**

ក្រសួង ស្ថាប័ននានា អាចធ្វើទំនាក់ទំនងនិងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលក្រុង ឬរដ្ឋបាលស្រុក ឬរដ្ឋបាលឃុំ ឬរដ្ឋបាលសង្កាត់ តាមការចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្ត។

**មាត្រា ១៩៩.-**

ក្នុងករណីមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង ឬជាមួយរដ្ឋបាលស្រុក ឬជាមួយរដ្ឋបាលឃុំ ឬជាមួយរដ្ឋបាលសង្កាត់ ឬរវាងរដ្ឋបាលណាមួយក្នុងចំណោមរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ ក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្របសម្រួលដោះស្រាយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២០០.-**

ក្នុងករណីមិនចុះសម្រុងគ្នារវាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត គ.ជ.អ.ប.ត្រូវសម្របសម្រួលដោះស្រាយ ផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្នុងករណីមិនអាចសម្របសម្រួលដោះស្រាយបាន គ.ជ.អ.ប. ត្រូវធ្វើសេចក្ដីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការត្រួតពិនិត្យការបំពុលខ្យល់
# និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ទនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបួប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្តើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

ជ-**"បរិមាណសារធាតុបំពុល"** គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-**"សារធាតុប្រកបដោយគ្រោះថ្នាក់"** គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

### មាត្រា ៤.-

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

### មាត្រា ៥.-

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៦.-

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

### មាត្រា ៧.-

ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

ក៏រិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

### មាត្រា ៨.-

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.-**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.-**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

# ជំពូកទី ៨
# អវសានបញ្ញត្តិ

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

*លេខ៖ ០២០ ផ.ក*

# ផែនការណែនាំ
## ស្តីពី
## ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ, ឃុំមានសុវត្ថិភាព"

*សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឲ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។*

*នាឱកាសមិទ្ទីញរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០* **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោលការណ៍កសាងភូមិ,* ***ឃុំមានសុវត្ថិភាព*** *ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រកល្ហក ទូទាំងព្រះរាជាណាចក្រកម្ពុជា ។*

*ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃបានកំណត់យកភូមិ,* ***ឃុំមានសុវត្ថិភាព*** *ធ្វើជាគោលនយោបាយអាទិភាពមួយសំរាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំទូទាំងប្រទេស ។*

*ដើម្បីអនុវត្តឲ្យបានជោគជ័យគោលនយោបាយខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្ត ដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖*

### I-<u>គោលបំណង និងសំណូមពរ ៖</u>

*១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំង*

ព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច នៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឲ្យកាន់តែបានល្អប្រសើរថែមទៀត ។

៤-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្ត **គោលនយោបាយភូមិ, ឃុំមានសុវត្ថិភាព** ។

## II-<u>លក្ខណៈសម្បត្តិ ភូមិ, ឃុំមានសុវត្ថិភាព</u>

***ភូមិ, ឃុំមានសុវត្ថិភាព គឺភូមិ, ឃុំដែលមានលក្ខណៈសម្បត្តិ ៥យ៉ាង ដូចខាងក្រោម៖***

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣-គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

## III-<u>វិធានការ និងផែនការសកម្មភាព</u>

### ក-<u>វិធានការ៖</u>

១-ចាត់វិធានការលុបបំបាត់ឲ្យបានបទល្មើសលួច ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការជំនាញ វិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឲ្យបានការផលិត ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារ ឲ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា (<u>ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និង</u>

ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឲ្យបានម៉ឺងម៉ាត់ ។

៤-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឲ្យបានទាន់ពេល និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ ០៤ស.រ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៩០៨.ក ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ-ផែនការសកម្មភាព៖**

១-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវអនុវត្តអោយបាននូវរបបប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការដាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ**ភូមិ, ឃុំមានសុវត្ថិភាព** ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំ លេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។

២-នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹងកងកម្លាំងនេះ ដើម្បីក្លាយទៅជាកំលាំងស្នូលពិតប្រាកដ នៃចលនាការពារ "**ភូមិ, ឃុំ មានសុវត្ថិភាព**" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ ៖

-ត្រូវរៀបចំឲ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាច ព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បងការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឲ្យមានទីកន្លែងធ្វើការ មធ្យោបាយ ឧបករណ៍សំភារៈសំរាប់បំរើការងារ និងរៀបចំឲ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្ដូរវេនប្រចាំការជាអចិន្ត្រៃយ៍នៅស្នាក់ការនគរបាលប៉ុស្ដិ៍រដ្ឋបាលដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណីមានសភាពការណ៍បទល្មើស ឬឧប្បទ្ទវហេតុផ្សេងៗកើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្ដុំកម្លាំងដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយកងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការសហការផ្ដល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការនយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គមនៃប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់ៗរូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រ សហការ ចូលរួមឲ្យបានទូលំទូលាយប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា**ភូមិ, ឃុំមានសុវត្ថិភាព** ។

**៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវ៖**

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទីនៃនគរបាលថ្នាក់នីមួយៗ ដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ជាប្រចាំ ។ ជាមួយនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវបញ្ជាអោយអង្គភាពនគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្ដិ៍រដ្ឋបាលឃុំ, សង្កាត់ នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឲ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយក**ភូមិ**ធ្វើជាគោលដៅ ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្ដាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឲ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើស រក្សា**សុវត្ថិភាពភូមិ, ឃុំ** ។

៤-ក្រោមការសំរបសំរួលរបស់រដ្ឋបាលឃុំ, សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនិមួយៗ ឬកម្រងភូមិត្រូវរៀបចំឲ្យមានវេទិកាសាធារណៈ **ស្ដីពីសុវត្ថិភាពភូមិ, ឃុំ** ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង ១ត្រីមាស (ឯកសារយោងផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "**ចលនាប្រជាការពារ**" លេខ ០៣៨ផក ចុះថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិការនេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយ

*មិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការឯកភាពរដ្ឋបាលថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ឲ្យបានសមស្របជូនប្រជាពលរដ្ឋវិញ ។*

***៥-ក្រសួងមហាផ្ទៃសូមអំពាវនាវ៖***

*-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន ចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការ លើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយក្រសួងមហាផ្ទៃ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។*

*-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ... ផ្អែកតាមតួនាទី ភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភ គាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាព ចូលរួមក្នុងការអនុវត្តគោលនយោបាយ **ភូមិ, ឃុំមានសុវត្ថិភាព** ។*

*៦-ត្រូវចាត់តាំងឲ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃអបអរសាទរសំរាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជាប្រចាំឆ្នាំនិមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" (ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា១៦ ឧសភា ១៩៤៥) ។*

**IV-ការចាត់តាំងអនុវត្ត៖**

*១-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បី សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដឹកនាំ និងចាត់តាំងអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព**នេះ ។ (ភ្ជាប់ជាមួយឧបសម្ព័ន្ធ) ។*

*២-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំអោយមានក្រុមការងារចុះតាមមូលដ្ឋានឃុំ សង្កាត់ ដោយយក**ភូមិ**ជាគោលដៅដើម្បីសហការអនុវត្តគោលនយោបាយ**ភូមិ, ឃុំ មានសុវត្ថិភាព** ។*

*៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "**ភូមិ, ឃុំ មានសុវត្ថិភាព**" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើរមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះ ដើម្បីមានមូលដ្ឋានវាយតម្លៃលទ្ធផល និងស្នាដៃតាមឃុំ សង្កាត់ និមួយៗ ។*

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ត្រូវចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និង លើកទិសដៅបន្តក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នក ពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការ ឯកភាពរដ្ឋបាលសំរេច ។

៥-ដើម្បីទទួលបានបទពិសោធន៍ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ, ឃុំមានសុវត្ថិភាពនេះ ឲ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ អាចជ្រើសរើសមូលដ្ឋានមួយ ឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និង ចាត់តាំងអនុវត្តជាទូទៅ ។

៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃ លក្ខណៈសម្បត្តិរបស់**ភូមិ, ឃុំ មានសុវត្ថិភាព** ។ តាមរយៈនេះត្រូវរកឲ្យឃើញអង្គភាព និងបុគ្គល ដែលមានស្នាដៃល្អ ដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

៧-អគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សំភារៈ បំរើដល់ ការចាត់តាំងអនុវត្តគោលនយោបាយភូមិ, ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយភូមិ, **ឃុំមានសុវត្ថិភាព**នេះ ក្រសួង មហាផ្ទៃសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ គណបក្ស នយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួម អនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យ ក្នុងការកសាងសេចក្តីសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១

# ផែនទីរដ្ឋបាលខេត្តកំពង់ចាម និងរដ្ឋបាលក្រុងកំពង់ចាម






# ឧបសម្ព័ន្ធទី២

# ទីតាំងសំខាន់ៗនៅក្នុងរដ្ឋបាលក្រុងកំពង់ចាម និងសោភ័ណភាពក្រុងកំពង់ចាម



ទីតាំង៖ សាលាខេត្តកំពង់ចាម




ទីតាំង៖ សាលាក្រុងកំពង់ចាម




ទីតាំង៖ រង្វង់មូលនាគព័ន្ធ




ទីតាំង៖ មន្ទីរពេទ្យខេត្តកំពង់ចាម




ទីតាំង៖ វិទ្យាល័យព្រះសីហនុ




ទីតាំង៖ ផ្សារធំក្រុងកំពង់ចាម

# ទីតាំង៖ សួនច្បារមាត់ទន្លេក្រុងកំពង់ចាម















សោភ័ណភាពពេលថ្ងៃ និងសោភ័ណភាពពេលយប់ក្នុងក្រុងកំពង់ចាម














# ឧបសម្ព័ន្ធទី៣

## សកម្មភាពរដ្ឋបាលក្រុងកំពង់ចាម












